CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមេសា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០១



## អបអរសាទរ
## បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍ក្នុងពិធីហែស្លឹក



ព្រះសហគមន៍កាតូលិកប៊ឺស្រា

នៅព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន





នៅព្រះសហគមន៍កាតូលិក កំពង់ធំ

នៅព្រះសហគមន៍កាតូលិក បាត់ដំបង



Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# អបអរសាទរឆ្នាំថ្មី និងរីករាយបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

សម្រាប់ឆ្នាំ២០១៧នេះ តាមប្រតិទិនរបស់ព្រះសហគមន៍កាតូលិកបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ចំថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសរីករាយអបអរសាទរឆ្នាំថ្មី ប៉ុន្តែគ្រីស្តបរិស័ទត្រូវរំឭកអំពីព្រះយេស៊ូរងទុក្ខលំបាក ហើយរង់ចាំថ្ងៃព្រះអង្គមានព្រះជន្មរស់ឡើងវិញ។

សម្រាប់គ្រីស្តបរិស័ទមិនមែនមានន័យថា យើងមិនចូលរួមអបអរសាទរឆ្នាំថ្មីនោះទេ តែគ្រាន់តែវាជាពេលវេលា ដែលយើងចូលរួមព្រឹត្តិការណ៍នៃទុក្ខលំបាករបស់ព្រះយេស៊ូដែលខ្លួនជាគ្រីស្តបរិស័ទត្រូវតែប្រារព្ធជារៀងរាល់ឆ្នាំ។ បុណ្យព្រះយេស៊ូរងទុក្ខលំបាករហូតដល់សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញជាបុណ្យកំពូលនៃជំនឿរបស់គ្រីស្តបរិស័ទ។ បើព្រះយេស៊ូសោយទិវង្គតមិនមានព្រះជន្មរស់ឡើងវិញទេនោះ គឺគ្មានគ្រីស្តបរិស័ទឡើយ។

ក្នុងឱកាសនេះដែរ យើងខ្ញុំក៏សូមអបអរសាទរជាមួយបងប្អូនប្រមាណជាង ៣០០នាក់ ដែលទទួលអគ្គសញ្ញាជ្រមុជទឹករួមស្លាប់រួមរស់ជាមួយព្រះយេស៊ូក្នុងឱកាសបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនេះដែរ។

ក្នុងជីវិតជាគ្រីស្តបរិស័ទត្រូវតែរស់នៅក្នុងជំនឿរបស់ខ្លួនជាប់ជាមួយព្រះយេស៊ូ។

ក្នុងឆ្នាំ២០១៧នេះ ព្រះសហគមន៍កាតូលិកប្រកាសជាឆ្នាំសម្រាប់គ្រួសារ។ គ្រួសារជាកោសិកានៃព្រះសហគមន៍ដែលមិនអាចខ្វះបាន ហេតុនេះព្រះសហគមន៍ត្រូវតែយកចិត្តទុកដាក់ណែនាំបងប្អូនគ្រីស្តបរិស័ទឲ្យកាន់តែយល់ច្បាស់ឡើងៗ អំពីសេចក្តីស្រឡាញ់ដែលមកពីប្រះជាម្ចាស់ក្នុងជីវិតជាគ្រួសារ។

គ្រួសារជាអំណោយទានពិសេសរបស់ព្រះសហគមន៍របស់ព្រះជាម្ចាស់។ គូស្វាមីភរិយា គ្រួសារស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក គេក្លាយទៅជារូបកាយតែមួយ ព្រោះស្វាមីត្រូវចេញពីឪពុកម្តាយទៅរស់នៅជាមួយភរិយា (កណ២, ២៤)។ ចេះស្តាប់ ផ្តល់យោបល់ ផ្តល់សេចក្តីស្រឡាញ់ទាំងរូបកាយ បេះដូង ព្រលឹង...ឲ្យគ្នាទៅវិញទៅមក។ ពួកគេត្រូវយកចិត្តទុកដាក់អប់រំកូនចៅតាមជំនឿកាតូលិកក្នុងសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដដែលបានមកពីព្រះជាម្ចាស់។ ម្នាក់ៗមានតួនាទីពិសេសរៀងៗខ្លួនក្នុងគ្រួសារ គឺគ្មាននរណាប្រសើរជាងនរណាឡើយ។ សូមលើកទឹកចិត្តគ្នាទៅវិញទៅមក។



**លោក លី សុវណ្ណា**
*ចាងហ្វាងកាសែតអ្នកនាំសារ*

សូមឲ្យសិរីរុងរឿងដែលកើតចេញពីទុក្ខលំបាក និងព្រះជន្មថ្មីរបស់ព្រះយេស៊ូណែនាំឲ្យបងប្អូនពោរពេញដោយពន្លឺអំណរសប្បាយ សុភមង្គល សេចក្តសុខសាន្ត និងវឌ្ឍនភាពជានិច្ច។ សូមឆ្នាំថ្មីនេះ លោកអ្នកបានពោរពេញដោយព្រះពរយ៉ាងបរិបូរ។

បងប្អូនដែលទើបទទួលជីវិតថ្មីពីព្រះជន្មផ្ទាល់របស់ព្រះអម្ចាស់យេស៊ូគ្រីស្តទៅជាពន្លឺដល់មនុស្សទាំងអស់។

សួស្តីឆ្នាំថ្មី!
រីករាយបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ!

# ពិធីបុណ្យព្រះយេស៊ូរងទុក្ខលំបាក (ហែស្លឹក) នៅព្រះសហគមន៍ជ្រៃធំ

ព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ ស្ថិតក្នុងស្រុកកោះធំ ខេត្តកណ្តាល នៃមណ្ឌលសកម្មភាពបាសាក់ របស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៧នេះ បានប្រារព្ធពិធីបុណ្យហែស្លឹក យ៉ាងឱឡារិក ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឝ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកបូជាចារ្យសិលាទីន ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពបាសាក់ព្រមទាំងមានការចូលរួមពីសំណាក់បងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

ក្រោយមានប្រសាសន៍ស្វាគមន៍លោកអភិបាលពីសំណាក់លោកបូជាចារ្យសិលាទីន ដែលជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ រួចមក។ បន្ទាប់មកចាប់ផ្តើមអធិដ្ឋានចូល ដោយប្រោះទឹកព្រះពរលើស្លឹក និងលើគ្រីស្តបរិស័ទ រួចធ្វើពិធីហែស្លឹកបានចាប់ផ្តើមដង្ហែពីបរិវេណដីព្រះពរ ដែលនៅខាងក្រោយព្រះវិហារ ចូលមកក្នុងព្រះវិហារដើម្បីថ្វាយអភិបូជា ដោយមានគ្រីស្តបរិស័ទ ដើរដង្ហែតាមពីក្រោយលោកអភិបាល និងលោកបូជាចារ្យ អមដោយបទចម្រៀងជយោ! ព្រះរាជវង្ស ព្រះបាទដាវីឌ ។

ថ្លែងនៅក្នុងឱកាសនោះ លោកអភិបាលអូលីវីយេ ឝ្មីតអឺស្លែរ បានមានប្រសាសន៍ថា ជីវិតរបស់យើងម្នាក់ៗ ជាប់ជាមួយព្រះយេស៊ូតាមរបៀបថ្មី។ នៅពេលដែលបណ្តាជនដើរតាមព្រះយេស៊ូ និងនៅជាមួយព្រះអង្គ គេជឿលើព្រះអង្គ ដែលនាំឲ្យពួកគេមានអំណរសប្បាយ គឺដោយសារតែពួកគេបានទទួលនូវម្ហូបអាហារ រីឯអ្នកជម្ងឺ អ្នកពិការ មនុស្សខ្វាក់ខ្វិន បានទទួលការប្រោសឲ្យជាសះស្បើយផងដែរ។ ចំណែកក្រុមស្រ្តីៗ ពួកគេក៏បានទទួលការសង្គ្រោះនោះដែរ។ ពេលព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ពួកគេអបអរព្រះអង្គ ដោយលើកតម្កើងព្រះអង្គប្រៀបបីដូចជា ព្រះមហាក្សត្រមួយអង្គ ដែលមានអំណាចនិងគ្រងរាជ្យនៅក្នុងលោកនេះ។ នៅពេលព្រះយេស៊ូរងទុក្ខលំបាក បែរជាពួកគេរត់ចោលព្រះអង្គ ហើយបដិសេធមិនទទួលស្គាល់ព្រះអង្គថែមទៀត។ ប៉ុន្តែយើងម្នាក់ៗមើលឃើញហើយថា ព្រះយេស៊ូបានលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីប្រោសបាបរបស់មនុស្សលោកទាំងអស់។

លោកអភិបាលបន្តថា តាមរយៈព្រឹត្តិការណ៍ទាំងឡាយរបស់ព្រះអង្គ គឺការ ដែលព្រះយេស៊ូប្រសូត និងការសោយទិវង្គតព្រមទាំងសក្ខីភាពជាច្រើន ដែលព្រះអង្គ បានបកស្រាយនិងបង្រៀន ពួកសាវ័ក ប៉ុន្តែពួកគេមិនយល់។ ព្រះអង្គតែងតែបញ្ជាក់យ៉ាងច្បាស់ថា គឺព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គផ្ទាល់ ទុកជាសក្ការបូជាដ៏ខ្ពង់ខ្ពស់។

លោកអភិបាលបានបញ្ជាក់ថា ជួនកាលយើងមានជំនឿរឹងមាំដូចលោកសិលាដែរ ហើយពេល ខ្លះយើងក៏បដិសេធចំពោះព្រះអង្គនោះដែរ។ តាមជំនឿរបស់យើង យើងជឿថា រឿងទុក្ខលំបាក របស់ព្រះយេស៊ូ ដែលយើងបានស្តាប់នៅថ្ងៃនេះ ក៏ជាទុក្ខលំបាករបស់យើងដែរ។ ក្នុងជីវិតរបស់ យើងម្នាក់ៗជួនកាលដូចជាលោកយ៉ូដាសអ៊ីស្ការីយ៉ុត ដែលក្បត់ព្រះអង្គជួនកាលយើងដូចលោកយ៉ូហាន ដូចទាហាន និងពេលខ្លះយើងក៏ដូចនាងម៉ារី ដែលចូលរួមជាមួយ និងទុក្ខលំបាករបស់ ព្រះយេស៊ូ ដែលនេះជាជីវិតពិតរបស់យើងម្នាក់ៗផ្ទាល់ ដែលរស់នៅក្នុងលោកនេះ។

ជាចុងក្រោយលោកអភិបាលបានមានប្រសាសន៍ដោយសង្កត់ធ្ងន់ថា ដោយព្រះយេស៊ូបានចាប់ កំណើតជាមនុស្ស និងបានសោយទិវង្គត ណែនាំឲ្យយើងម្នាក់ៗមានជីវិត ដែលនេះជាអាថ៌កំបាំង។ សូមព្រះអង្គប្រទានពរដល់យើងម្នាក់ៗ ដោយតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធជួយណែនាំយើងឲ្យក្លាយ ទៅជាអ្នកបម្រើដ៏ស្មោះត្រង់ ហើយប្រទានជីវិតឲ្យយើងក្នុងសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះអង្គ ។

សូមបញ្ជាក់ថា ក្នុងពិធីថ្វាយអភិបូជានោះផងដែរ លោកអភិបាលក៏បានធ្វើការអធិដ្ឋាន ដោយទូលអង្វរព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ សូមព្រះអង្គប្រទានពរដល់សមាជិកគណៈកម្មាធិការថ្មី របស់ព្រះសហគមន៍ជ្រៃធំ ចំនួន១៤ នាក់ ដែលបានលះបង់កម្លាំងកាយចិត្ត ចូលរួមបម្រើព្រះសហគមន៍នៅក្នុងជួរគណៈកម្មការផ្សេងៗ សម្រាប់អណត្តិថ្មីនេះ៕

*ដោយ ឡុង សម្ផស្ស*



# តម្លៃទំនិញនិងក្តីរំពឹងអំពីការចំណាយរបស់ពលរដ្ឋនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

នៅខែមេសា ជារៀងរាល់ឆ្នាំប្រជាពលរដ្ឋនៅក្នុង ប្រទេសកម្ពុជាតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឬអាចហៅបានថា សង្ក្រានឆ្នាំថ្មី ដូច្នេះនារដូវកាលនេះ ត្រូវបានគេដឹងថា គឺជាពេលវេលាមួយ ដែលពលរដ្ឋកម្ពុជា ត្រូវចំណាយយ៉ាងច្រើន។

នាឆ្នាំនេះ ស្របពេលដែលពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរការ នឹងឈានចូលមកដល់នៅវេលាម៉ោង៣:១២នាទីទាបភ្លឺ ត្រូវនឹងថ្ងៃសុក្រ ទី១៤ ខែមេសា ឆ្នាំ២០១៧ ដែលតាមជំនឿទេវតារក្សាឆ្នាំថ្មី ព្រះនាមកិមិរាទេវី ជាបុត្រីទី៦ នៃកបិលមហាព្រហ្មទ្រង់សោយ ចេកណាំវ៉ា ឬចេកទឹក ប៉ុន្តែជាទូទៅនៅមុនពេលដែលពិធីចូលឆ្នាំថ្មីប្រពៃណីជាតិនេះបានចូលមកដល់នោះ ការចំណាយជាច្រើនត្រូវបានប្រជាពលរដ្ឋកម្ពុជាចាប់ផ្តើមចេញតាំងពីពេលមុនចូលឆ្នាំថ្មី។

អ្នកស្រី មី សុគន្ធារី ដែលជាអាជីវករលក់ដូរផ្លែឈើ ស្ថិតក្នុងផ្សារធំថ្មី បានឲ្យដឹងថា បើតាមការរំពឹងទុករបស់អ្នកស្រី ដោយសារតែឆ្នាំនេះ យើងទាំងអស់គ្នាមានជំនឿថា ទេវតាឆ្នាំថ្មីសោយចេក ណាំវ៉ាបែបនេះ ទំនិញ ជាពិសេសគឺចេកណាំវ៉ានឹងឡើងថ្លៃមិនខាន។

លោកស្រីក៏នៅមិនទាន់ដឹងថា តើតម្លៃនៃចេកណាំវ៉ានៅពេល ដែលថ្ងៃចូលឆ្នាំថ្មីមកដល់តម្លៃប៉ុន្មានដែរ ប៉ុន្តែ នៅពេលបច្ចុប្បន្ននេះ តម្លៃចេកណាំវ៉ា ក្នុងមួយស្និត មានតម្លៃចាប់ពី ២០.០០០រៀលដែលជាតម្លៃបោះដុំ និងតម្លៃចាប់ពី ២៥.០០០ រៀល ដែលជាតម្លៃលក់រាយ។

ក្រៅពីផ្លែចេកណាំវ៉ា ដែលជារណ្តាប់ទទួលទេវតាឆ្នាំថ្មី នៅមានដូចជា ពាក្យស្លោកថា សួស្តីឆ្នាំថ្មី គោមរូបផ្កាយ សម្រាប់តាំងលម្អ បាយសី ដូងក្រអូប នឹងផ្កាម្លិះ ភេសជ្ជៈ និងទំនិញជាច្រើនមុខទៀត។

ពាក្យស្លោកសួស្តីឆ្នាំថ្មី ត្រូវបានភ្ជួរយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្នុងស្តង់ទំនិញស្ថិតក្នុងផ្សារធំថ្មីដដែល ត្រូវបានដាក់តាំងបង្ហាញសម្រាប់ការលក់ជូនប្រជាពលរដ្ឋខ្មែរ យកទៅប្រើប្រាស់ជាគ្រឿងតាំងលម្អគេហដ្ឋាន។

បងស្រី សុវណ្ណ នារីរត្ន័ ដែលជាអាជីវករកំពុងលក់ដូរនូវ ពាក្យស្លោកខាងលើ បានថ្លែងថា សម្រាប់ពាក្យស្លោក នេះមានតម្លៃ ២០.០០០រៀល ទៅ៣០.០០០រៀលទៅតាមទំហំ សម្រាប់ទំហំតូច រីឯទំហំធំ មានតម្លៃ ៤០.០០០រៀល ឬ១០ដុល្លារ។

អ្នកស្រី សុខ សុធាវ៉ា ដែលជាម្ចាស់សិប្បកម្ម ផលិតគោម ខ្មែរមួយកន្លែង ស្ថិតនៅក្នុង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញបានមានប្រសាសន៍ ពាក់ពន្ធ័នឹងគោមខ្មែរនេះថា គោមនេះផលិតឡើងពីឬស្សី បិទដោយដៃសិប្បករខ្មែរ នឹងត្រូវបានពាសដោយផ្លាស្ទិក ដែលជាវត្ថុធាតុដើមនាំចូល ពីបរទេស។

អ្នកស្រី បានបន្តថា នៅក្នុងឆ្នាំនេះ តម្រូវការគោមខ្មែរ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលត្រូវបានគាំទ្រពីសំណាស់ប្រជាពលរដ្ឋខ្មែរទាំងប្រុសទាំងស្រី ដែលធ្វើការយកទៅតាំងលម្អគេហដ្ឋាន សម្រាប់ឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិយើងនេះ។

ដោយឡែកម្ចាស់ស្តង់ ដូងក្រអូបស្ថិតក្នុងសង្កាត់ វាលវង់ ខណ្ឌប្រាំពីរ មករា លោកហេង សុធីវ៉ាន់ បានថ្លែងដូចនេះថា ដូងក្រអូបត្រូវបានយកមកពីខេត្តកំពត ដែលមានតម្លៃ ៥.០០០រៀលក្នុងមួយផ្លែ សម្រាប់ការលក់រាយ នឹងតម្លៃ ៤.០០០រៀល សម្រាប់ការលក់ដុំ។

ម្ចាស់ស្តង់ ដូងក្រអូបខាងលើ បានបន្តថា តម្រូវការដូង ពិតជាមានតម្រូវការច្រើនខ្លាំងបើទោះបី ជាមិនមែនជារដូវកាលចូលឆ្នាំថ្មីក៏ដោយ ប៉ុន្តែបើនៅពេលចូលឆ្នាំវិញពិតជាមានតម្រូវការកាន់តែខ្លាំងឡើងបន្ថែម ដែលពេលខ្លះអាចមានការដាច់អស់ពីក្នុងស្តុកទៀតផង។

កញ្ញា អ៊ុង សុភារី បានថ្លែងថា ផ្កាម្លិះជាផ្កាដែលចាំបាច់បំផុតដែល ក្នុងពេលពិធីបុណ្យចូលឆ្នាំថ្មី ដោយផ្កាម្លិះមានក្លិនក្រអូប ហើយមានតម្រូវការទាំងមុន នឹងក្រោយពេលពិធីបុណ្យចូលឆ្នាំថ្មី ដែលមានតម្លៃចាប់ពី ១០០.០០០រៀល ទៅ ១៥០.០០០ រៀល ក្នុងមួយគីឡូក្រាម។

ដោយឡែក កញ្ញា ទិត ស៊ីណែត អ្នកលក់ផ្កាម្លិះដូចគ្នា បានថ្លែងផងដែរថា ផ្កាម្លិះក្នុងឆ្នាំនេះមានតម្លៃរាងខ្ពស់ជាងឆ្នាំទៅដោយចាប់ពី១២០.០០០ រៀល ទៅ ១៥០.០០០ រៀល ក្នុងមួយគីឡូក្រាម។

ក្រៅពីទំនិញទាំងនេះ នៅមានទំនិញជាច្រើនប្រភេទទៀតដែលប្រជាពលរដ្ឋត្រូវទិញ ហើយក៏នៅមានការចំណាយសម្រាប់ការធ្វើដំណើរ ការចំណាយសម្រាប់ពេលកំសាន្ត និងការចំណាយធ្វើបុណ្យធ្វើទាន ការចំណាយជូនចាស់ទុំ និងញាតិសណ្តានព្រមទាំងឪពុកម្តាយថែមទៀត នេះបើតាមការលើកឡើងរបស់លោកស្រី ទុំ កណិការ ដែលជាប្រជាពលរដ្ឋវ័យ ៦២ ឆ្នាំមួយរូប។

លោកស្រី កណិការ បានមានប្រសាសន៍ថា ជាទូទៅការចំណាយនៅតាមគ្រួសារគឺច្រើនទៅតាមស្ថានភាព និងជីវភាព រៀងខ្លួន ប៉ុន្តែសម្រាប់គ្រួសារលោកស្រីនៅក្នុងមួយឆ្នាំៗ សម្រាប់ការចំណាយនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះ គឺមិនក្រោមពី ៤០០ ទៅ៥០០ ដុល្លារទេ។

លោកស្រីបានរៀបរាប់ខ្ទង់ចំណាយ ដែលរំពឹងថា នឹងត្រូវចំណាយនាសប្តាហ៍ក្រោយនេះថា គ្រាន់តែថ្លៃរណ្តាប់សម្រាប់ទទួលទេវតា មានផ្កាភ្ញី ភេសជ្ជៈ ផ្លែឈើ នំនែក គ្រឿងកំប៉ុង ភេសជ្ជៈនេះ គឺមិនក្រោមពី ៣០ ទៅ៥០ដុល្លារទេ ចុះនៅថ្លៃម្ហូបអាហារទៅវត្ត ២០ ទៅ៣០ដុល្លារ ថ្លៃភេជ្ជៈ ទឹកក្រូច ស្រាបៀរ សម្រាប់ទទួលទាន ជូនគ្រួសារ និងមិត្តភ័ក្រព្រមទាំងកូនចៅមកលេងជុំគ្នា ២០ ទៅ៣០ដុល្លារទៀត ចុះនៅថ្លៃ សាំងឡាន ១០០ដុល្លារ ថ្លៃហូបចុកស្នាក់នៅពេលដើរលេង ថ្លៃជូនចាស់ទុំ ឪពុកម្តាយ ថែមទៀត ៤០០ ទៅ ៥០០ ដុល្លារ គឺជួនកាន់ខ្វះផង។

លោកស្រីបានបញ្ជាក់ថា "នេះសម្រាប់គ្រួសារខ្ញុំ តែមិត្តភ័ក្រខ្ញុំខ្លះ គឺទៅលេងនៅបរទេស ទាំងគ្រួសារថែមទៀត គឺចូលរាប់ពាន់ដុល្លារ ប៉ុន្តែសម្រាប់អ្នកដែលខ្សត់ក៏តិចឬ ច្រើនតាមហ្នឹងទៅ"។

លោក នេត សារឿន ជាប្រជាពលរដ្ឋកម្ពុជាមួយរូប ដែលមានវ័យ ៤៥ឆ្នាំ បានថ្លែងថា បើនិយាយអំពីការចំណាយរបស់ប្រជាពលរដ្ឋខ្មែរសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិគឺច្រើន។

លោកបានថ្លែងថា សម្រាប់លោកមិនទាន់បានគិតថា អស់ប៉ុន្មាននោះទេ ប៉ុន្តែដឹងថាច្រើន គ្រាន់តែភេជ្ជៈ និងគ្រឿងកំប៉ុងដែលលោកទិញសម្រាប់ចែកជូនចាស់ៗ គឺ ចូលប្រមាណជា ៣០០ដុល្លារហើយ ចុះនៅស្រោមសំបុត្រថែមទៀត ។

លោកជិន មករា ជាអ្នករត់ម៉ូតូឌុបមួយរូប បានថ្លែងថា ការចំណាយរបស់លោក និងគ្រួសារគឺមិនច្រើនដូចគេទេ ប៉ុន្តែក៏មិនជាតិចដែរ។

លោកបានបញ្ជាក់ថា "ឆ្នាំនេះខ្ញុំមាន ៤០០.០០០ទៅ ៥០០.០០០ សម្រាប់ចូលឆ្នាំថ្មីសប្បាយនឹងគេ"។

លោកបានបន្តថា លុយនេះប្រហែលជាមិនច្រើនទេ សម្រាប់គេដែលមានជីវភាពធូធារ ប៉ុន្តែ នេះជាលុយសន្សំ ដែលលោកអាចធ្វើបានសម្រាប់ថ្ងៃបុណ្យចូលឆ្នាំប្រពៃណី ជាតិនាពេលខាងមុខ ។

បើយោងតាមប្រតិទិនឈប់សម្រាកសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មីនេះ គឺចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៧ ។

*ដោយ ផានិត និងអរិយបុត្រ*



*ថតដោយ សម្បត្តិ*

# យុវជនខ្មែរហាក់នឿយណាយនឹងល្បែងប្រជាប្រិយ



ថតដោយ សុធីរិទ្ធិ

ចោលឈោង ទាញព្រ័ត្រ លាក់កន្សែង បោះអង្គុញ ស្ដេចចង់ គឺសុទ្ធសឹងតែជាល្បែងប្រជាប្រិយខ្មែរ ដែលគេតែងតែនិយមលេងនៅពេលដែលរដូវចូលឆ្នាំជិតមកដល់ និងក្នុងពេលរៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ ប៉ុន្តែសម័យបច្ចុប្បន្ននេះ យុវជនខ្មែរហាក់ដូចជានឿយណាយនៅក្នុងការលេងល្បែងប្រជាប្រិយទាំងនេះ។

លោក ហ៊ិន ចំណាន ជាអតីតមន្ត្រីរាជការមួយរូបបានថ្លែងថា ល្បែងប្រជាប្រិយទាំងនេះហាក់ដូចជា ត្រូវបានក្រុមយុវជនសម័យបច្ចុប្បន្ននេះបំភ្លេចចោលេ ដោយសារតែតាមទីសាធារណៈ សាលារៀនជាដើម ហាក់កម្រឃើញក្មេងៗ គេលេងណាស់។

លោកបានបញ្ជាក់ថា "កាលសម័យ ខ្ញុំនៅក្មេង គេលេងពេញតែសាលា ឲ្យតែជិតដល់ពេលចូលឆ្នាំបែបនេះ ប៉ុន្តែឥឡូវស្ងាត់ឲ្យជ្រាប"។

លោកបន្តថា តាមការសង្កេតរបស់លោកនៅក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិបីបួនឆ្នាំជាប់ៗគ្នាមកល្បែងប្រជាប្រិយខ្មែរហាក់ដូចជាមិនសូវឃើញមានអ្នកលេងទេ។

លោកបានឲ្យដឹងថា នៅមុនសម័យនេះ នាម្តុំវត្តភ្នំអី គឺសំបូរឃើញក្មេងៗជួបជុំគ្នាលេងល្បែងទាំងនេះណាស់ ប៉ុន្តែសម័យនេះ ដូចជាឃើញគេលេងប៉ាតម្សៅវិញ។

លោកបានបញ្ជាក់ទៀតថា " ល្បែងប្រជាប្រិយទាំងនេះ ប្រហែលជានៅលេងខ្លះ សំបូរតែនៅក្នុងកម្មវិធីទូរទស្សន៍ និងខាវ៉ាអូខេតែប៉ុណ្ណឹង"។

ទេព សុបញ្ញាបុត្រ ជាយុវជនកំពុងតែបោះជំហានចេញពីកន្លែងរៀនគួរមួយកន្លែងនៅម្តុំសាលា វិទ្យាល័យបាក់ទូក បានឲ្យដឹងថា សាលាគាត់ដូចជាមិនមានអ្នកណាលេងអីផង ទោះបីជាពេលនេះជិតដល់ពេលសម្រាកវិសមកាលតូចក៏ដោយចុះ។

សុបញ្ញាបុត្រ បាននិយាយថា គាត់ក៏ចង់លេងល្បែងនេះដែរ ព្រោះឃើញ និងឮតែនៅក្នុងទូរទស្សន៍ ប៉ុន្តែមិនដែលបានលេងនឹងគេ។

យុវជនរូបនោះបានបន្តទៀតថា ប្អូននិងមិត្តភិក្តធ្លាប់លេងបោះអង្គុយ តែការលេងល្បែងប្រជាប្រិយឯទៀត ហាក់ដូចជាមិនដែល ដោយសារតែអត់ចេះលេង។ ដូចជាលេងចោលឈូងអីគឺថា ទាល់តែចេះច្រៀងបានលេងសប្បាយ។

ឈ សុវណ្ណារ៉ា ជាយុវជនដែលកំពុងតែសិក្សាផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យាមួយរូបបានឲ្យដឹងថា កាលនៅរៀនវិទ្យាល័យតាមខេត្តគឺធ្លាប់លេង តែតាំងពីមករៀននៅភ្នំពេញ៣ឆ្នាំហើយ មិនដែលបានលេងទេ។

សុវណ្ណារ៉ាបានឲ្យដឹងថា "កាលនៅរៀននៅខេត្ត ខ្ញុំលេងតើ បោះអង្គុញ ចោលឈូង និងទាញព្រ័ត្រ តែនៅមករៀននៅភ្នំពេញដូចជាស្ងាត់"។

លោកស្រី ណៃ ណារិន ជាអាជីវកម្មួយរូបនៅផ្សារតូចបានថ្លែងថា វាពិតជាស្ងាត់មិនសូវឃើញមែន រឿងល្បែងប្រជាប្រិយនេះ ប៉ុន្តែបែជាលិចចេញល្បែងថ្មី គឺចាក់ទឹកនិងប៉ាតម្សៅទៅវិញ។

លោកស្រី បានបញ្ជាក់ថា "អាល្បែងថ្មីហ្នឹងគឺហាក់ដូចជាផុលផុស ហើយឃើញមានច្រើនប៉ុន្មានឆ្នាំចុងក្រោយនេះ"។

លោកស្រីបានបន្តថា តាមដែលលោកស្រីចាំកាលពីពីរបីឆ្នាំមុន លោកស្រីធ្លាប់យកអង្គុញមកលក់ដែរ ប៉ុន្តែគ្មានអ្នកណាសួរទិញទេ។

លោកស្រីបានបន្តទៀតថា សូម្បីតែកូនខ្ញុំ ក៏វាមិនស្គាល់អង្គុញដែរ។

លោកស្រីបានបន្តថា "កាលខ្ញុំយកអង្គុញមកលក់ បើតាមមីងចាំ កូនមីងអាពៅ ដែលកាលនោះ វាមានអាយុ ១២ ឆ្នាំវាសួរអាហ្នឹងផ្លែស្អីអាចញ៉ាំបានអត់"។

កញ្ញាជុំ ស្រីល្មក្រ ជាកម្មការនីរោងចក្រកាត់ដេរ មួយរូបដែលមកពីខេត្តតាកែវ បានអះអាងថា នៅស្រុករបស់កញ្ញាគឺនៅមានលេងល្បែងទាំងនេះ ប៉ុន្តែមិនទាំងអស់ទេ។

កញ្ញាបានបន្តថា អាល្បែងបោះអង្គុយនេះ គឺនៅមានលេង ប៉ុន្តែគ្រាន់តែមិនសូវច្រើន ចោលឈូងក៏នៅមានដែរ ប៉ុន្តែការចាក់ធុងបាសរាំ និងលេងប៉ាតម្សៅ គឺមានអ្នកលេង និងគាំទ្រច្រើន។

ជុំវិញការលេងល្បែងប្រជាប្រិយទាំងនេះ កញ្ញា បានចែករំលែកអារម្មណ៍ផ្ទាល់របស់កញ្ញាថា ការលេងល្បែងប្រជាប្រិយទាំងនេះ គឺសប្បាយ ម៉្យាង ប៉ុន្តែវាធុញនឹងចំណុចអសកម្មមួយចំនួនរបស់អ្នកលេងខ្លះដែលមានគំនិតខូច។

កញ្ញា បាន បន្ថែមថា ដូចជាការលេងបោះអង្គុយអីចឹង អ្នកខ្លះគាត់ខូចពេលឈ្នះគេ ដោះគេ ដោះខ្ញុំនេះហើមៗជង្គង់ ពេលខ្លះឈឺ ដើរមិនចង់កើតក៏មាន ដូច្នេះហើយក៏ចេះតែ ពង្វៀងមិនចង់លេង ដោយឡែករឿងលេងឈូងក៏ដូចគ្នាដែរ។ តាមការពន្យល់ពេលមើលទូរទស្សន៍អីគឺ ល្បែងប្រជាប្រិយដូចជា ចោលឈោង លាក់កន្សែង ស្តេចចង់អី អត្ថន័យល្អ ប៉ុន្តែវាយ៉ាប់ត្រង់យើងលេងច្រើនតែប្រឡំ ដូច្នេះក៏ចេះតែខ្ជិលទៅ។

ដោយឡែកទាក់ទិននិងល្បែងថ្មីៗដែលបានលេចចេញហើយ ដែលគេនិយមលេងនៅក្នុងអំឡុង ប៉ុន្មានឆ្នាំចុងក្រោយនាពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ គឺចាក់ទឹកនិងប៉ាតម្សៅវិញល្មក្របាន អះអាងថា កញ្ញាមិនចូលចិត្តលេងទេ ប៉ុន្តែកញ្ញា ត្រូវគេលេងជាមួយរាល់តែដង។

កញ្ញាបានបន្តថា អាល្បែង ហ្នឹងទោះបីជាយើងមិនចង់លេង តែគេលេងជាមួយយើងគឺត្រូវតែសើម និងសពព្រុះពេញក្បាល ពេញខ្លួនពេញខោអាវ។

ជុំវិញល្បែងប្រជាប្រិយទាំងនេះ លោក សំហេង បុរស អនុប្រធានក្រុមការងារប្រតិបត្តិនៃព្រឹត្តិការណ៍ អង្គរសង្ក្រាន្តឆ្នាំ ២០១៧ បានឲ្យដឹងថា ព្រឹត្តិការណ៍អង្គរសង្ក្រាន្តជាព្រឹត្តិការណ៍ ដែលរៀបចំឡើងដើម្បីចូលរួម អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងផ្តល់នូវការសប្បាយ រីករាយជួបជុំគ្នាតាមរយៈ ការបង្ហាញអំពីល្បែងប្រជាប្រិយ របាំប្រពៃណីទំនៀមទម្លាប់នៃការរស់នៅរបស់ប្រជាជនខ្មែរ សិល្បៈទស្សនីយភាពផ្សេងៗ។

លោកបានបញ្ជាក់ថា "នេះជាព្រឹត្តិការណ៍ដើម្បីឱ្យយុវជន ប្រជាពលរដ្ឋខ្មែរក៏ដូចជាជាតិសាសន៍ដទៃ បានឈ្វេងយល់ពីមរតក អរិយធម៌ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីខ្មែរ ហើយរួមគ្នាថែរក្សាអភិរក្ស និងលើកតម្កើង។

លោកបានបន្តថា ល្បែងប្រជាប្រិយខ្មែរផ្សេងៗនឹងត្រូវបង្ហាញនៅក្នុងពិធីនេះ រួមនឹងកម្មវិធីជាច្រើន ក្រុមការងារបានកំពុងតែត្រៀមរៀបចំ។

*ដោយ អរិយបុត្រ*

# ពិធីសម្ពោធអគារស្នាក់នៅ របស់ក្រុមគ្រួសារបងស្រីប្រៀនប្រដៅនៃព្រះគ្រីស្ត នៅខេត្តពោធិ៍សាត់




ថតដោយ ឡុង សម្ផស្ស

ក្រុមគ្រួសារបងស្រី ប្រៀនប្រដៅនៃព្រះគ្រីស្ត នៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ កន្លងទៅ បានរៀបចំកម្មវិធីសម្ពោធអគារស្នាក់នៅរបស់ខ្លួន ក្រោមអធិបតីភាពលោក អេនរីគេ ហ្វីការេដូ (គីគេ) អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោកបូជាចារ្យ បងប្រុសបងស្រី ព្រមទាំងអាជ្ញាធរមូលដ្ឋានសង្កាត់បន្ទាយក្តី ក្រុងពោធិ៍សាត់ រួមនិងបងប្អូនគ្រីស្តបរិស័ទ នៃព្រះសហគមន៍កាតូលិក ខេត្តពោធិ៍សាត់យ៉ាងច្រើនកុះករ។

ថ្លែងក្នុងឱកាសនោះលោកអភិបាល គីគេ បានមានប្រសាសន៍ថា នៅថ្ងៃនេះ យើងទាំងអស់គ្នាពិតជាមានក្តីអំណររំភើប និងរីករាយ ដោយសារយើងបានឈានមកដល់ដំណាក់កាលនេះ គឺបានល្អហើយ។ សម្រាប់ក្រុមគ្រួសារបងស្រីប្រៀនប្រដៅនៃព្រះគ្រីស្ត នៅពេលនេះមានទីតាំងមួយដ៏ល្អ និងសមរម្យ សម្រាប់ការធ្វើសកម្មភាពនានា ជួយដល់កុមារ យុវជន និងប្រជាពលរដ្ឋនៅក្នុងតំបន់នេះ។

លោកអភិបាលបន្តថា ផ្ទះនេះ នាំឲ្យបងស្រីអាចប្រៀបធៀបដូចជា ផ្ទះនៅស្រុកកំណើត របស់បងស្រីផ្ទាល់ នៃប្រទេសកូរ៉េ។ ផ្ទះនេះប្រៀបដូចជា ដំណាក់របស់ព្រះជាម្ចាស់ នៅក្នុងការ ទំនាក់ទំនង និងការជួយបងប្អូនលើការអប់រំ។ ផ្ទះនេះក៏ជួយលើកទឹកចិត្តក្រុមបងស្រីផងដែរ ក្នុងការជួយបង្រៀនក្មេងៗ ដោយឲ្យពួកគេយកចិត្តទុកដាក់ក្នុងការរៀនសូត្រ។ យើងម្នាក់ៗមានសេចក្តីសង្ឃឹមថា ព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា។

លោកអភិបាល មានប្រសាសន៍ទៅកាន់ក្រុមបងស្រីថា គឺនៅពេលបងស្រីមានបេសកកម្ម គឺជាឱកាសរបស់បងស្រីនៅក្នុងការអធិដ្ឋានដោយយកពេលវេលាមានទំនាក់ទំនងជាប់ជានិច្ចជាមួយព្រះជាម្ចាស់។ ហើយរាល់ការប្រព្រឹត្តនានារបស់បងស្រី គឺជាការបង្ហាញខ្លួន និងបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនជាគ្រីស្តបរិស័ទ ទាំងពាក្យសំដី ការរស់នៅដែលជាវត្តមានរបស់ព្រះជាម្ចាស់ គឺបង្ហាញនូវព្រះភ័ក្ត្រព្រះយេស៊ូដោយបង្ហាញ សេចក្តីស្រឡាញ់ ចិត្តមេត្តាករុណា កិច្ចស្វាគមន៍អ្នកក្រីក្រ ការអប់រំ និងការជួយការពារបរិស្ថានជាដើម។ លោកអភិបាលបន្ថែមថា របៀបបម្រើអ្នកដទៃរបស់បងស្រី គឺជាការបង្ហាញនូវភក្តីភាពរបស់ព្រះជាម្ចាស់ គឺរាល់ពេលដែលយើងជួយអ្នកក្រីក្រ អ្នកជំងឺ គឺបង្ហាញព្រះហឫទ័យរបស់ព្រះជាម្ចាស់ផ្ទាល់។ ម៉្យាងវិញទៀតជីវិតនៃការអប់រំជំនឿនេះ យើងបានបង្ហាញអំពីភក្តីភាពចំពោះព្រះយេស៊ូ ដោយចែករំលែកជីវិតរបស់យើងដល់អ្នកដទៃ។ នៅក្នុងជីវិតរបស់ យើងមិនអាចខ្វះបាននូវចំណុចទាំងនេះ ដែលជួយយើងក្នុងការបង្ហាញព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

ជាមួយគ្នានេះបងស្រីប្រធាន សូមថ្លែងអំណរគុណដល់លោកអភិបាល គីគេ លោកបូជាចារ្យ បងប្រុស បងស្រី ព្រមទាំងអាជ្ញាធរមូលដ្ឋានសង្កាត់បន្ទាយក្តី ក្រុងពោធិ៍សាត់ ព្រមទាំងបងប្អូនគ្រីស្តបរិស័ទ បានជួយគាំទ្រនូវសកម្មភាពនានា របស់ក្រុមគ្រួសារបងស្រីដែលរស់នៅទីនេះ។

លោកចៅសង្កាត់បន្ទាយក្តី ក្រុងពោធិ៍-សាត់ បានមានប្រសាសន៍ចាប់អារម្មណ៍ថា ក្នុងនាមរូបលោកជាថ្នាក់ដឹកនាំអាជ្ញាធរមូលដ្ឋាននេះ លោកសូមគាំទ្រនូវសកម្មភាពទាំងឡាយរបស់ក្រុមគ្រួសារ បងស្រីកូរ៉េ ដែលបានធ្វើសកម្មភាពក្នុងការជួយដល់កុមារ និងយុវជនលើកិច្ចការអប់រំផ្សេងៗ នៅក្នុងមូលដ្ឋានរបស់លោក។ លោកក៏រីករាយ ក្នុងការសហការជាមួយបងស្រី ដើម្បីឲ្យកិច្ចការទាំងឡាយ បានក្លាយទៅជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននេះ។

បងស្រីដូមីនិក ជាប្រធានក្រុមគ្រួសារបងស្រីប្រៀនប្រដៅនៃព្រះគ្រីស្ត នៅប្រទេសកម្ពុជាបានមានប្រសាសន៍ឲ្យដឹងថា ក្រុមគ្រួសារបងស្រីប្រៀនប្រដៅនៃគ្រីស្ត បានមកដល់ប្រទេសកម្ពុជា អស់រយៈពេល៧ឆ្នាំកន្លងមកហើយ ដែលក្រុមគ្រួសារបងស្រីមកដល់ព្រះសហគមន៍ខេត្តពោធិ៍សាត់ នៅឆ្នាំ២០១២ ដោយបានចាប់ផ្តើមសកម្មភាពជាមួយ និងកម្មវិធីសាលាមត្តេយ្យក្នុងព្រះសហគមន៍កាតូលិកខេត្តពោធិ៍សាត់។

បងស្រីបន្តថា បងស្រីមើលឃើញថា មានគ្រួសារខ្មែរជាច្រើន ជាពិសេសនៅក្នុងខេត្តពោធិ៍សាត់ ពួកគេមានជីវភាពក្រីក្រ ហើយមានក្មេងៗជាច្រើននាក់ ពួកគេមិនបានរៀនសូត្រឡើយ ដោយគ្មានអ្នកណាជួយពួកគេនោះទេ។ ដូច្នេះក្រុមគ្រួសារបងស្រីបានចាប់ផ្តើមជាមួយកម្មវិធីអប់រំនៅសាលាបឋមសិក្សា សាលាមត្តេយ្យ រៀបចំបណ្ណា-ល័យនៅតាមភូមិចំនួន៥ និងឧបត្ថម្ភកុមារឲ្យបានរៀននៅសាលារដ្ឋ។ ដោយជួយអ្នកក្រីក្រ ចាស់ជរា ស្ត្រីមេម៉ាយ ក្មេងកំព្រា និងជួយសាងសង់ផ្ទះជូនគ្រួសារក្រីក្របានមួយចំនួនផងដែរ។

បងស្រីបន្ថែមថា ជារៀងរាល់ថ្ងៃអាទិត្យ បងស្រីបានជួយអប់រំជំនឿក្មេងៗ នៅព្រះវិហារហើយ មានសកម្មភាពមួយចំនួនទៀត គឺអប់រំជំនឿផង និងជួយបង្រៀនភាសាអង់គ្លេសដល់ពួកគេផង។ សម្រាប់ទីតាំងមណ្ឌលរបស់បងស្រីនេះ គឺបងស្រីសូមទទួលស្វាគមន៍ សម្រាប់ការអញ្ជើញមករៀបចំកម្មវិធីជួបជុំគ្នាអធិដ្ឋាន ឬសំណាក់ធម៌ជាដើម។

ជាចុងក្រោយបងស្រីដូមីនិក បញ្ជាក់ឲ្យដឹងថា សម្រាប់ដីមួយផ្នែកនៃទីតាំងនេះ នៅឆ្នាំក្រោយ បងស្រីមានគម្រោង រៀបចំមណ្ឌលមួយ ដែលមានឈ្មោះ មណ្ឌលសន្តិអាណា សម្រាប់ជួយដល់ សិស្សក្រីក្រ ដើម្បីជួយឲ្យ ពួកគេមានទីកន្លែងស្នាក់នៅ និងសិក្សារៀនសូត្រ ៕ *ដោយ ឡុង សម្ផស្ស*

# សំ សុភាពក្លាយជាប៉ូលីសចរាចរណ៍ស្ត្រី ព្រោះចង់ជួយសង្គម



ថតដោយ សុផានិត

*នៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះមុខរបរមានច្រើននៅក្នុងនោះមានទាំងពីមន្ត្រីរាជការស៊ីវិល ដែលជាអ្នកគ្រូពេទ្យ គ្រូបង្រៀន ឬកងកម្លាំងប្រដាប់អាវុធ ពាណិជ្ជករ ធនាគារិក ជាដើម ប៉ុន្តែនៅក្នុងចំណោម មុខរបរទាំងនេះ លេខនេះ អ្នកនាំសារសូមណែនាំមិត្តអ្នកអានជួបជាមួយនឹងមន្ត្រីប៉ូលីសជាស្ត្រីមួយរូប ដែលកំពុងតែមមាញឹកនឹងកិច្ចការដ៏សំខាន់មួយនៅលើទ្រូងផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កញ្ញាឈ្មោះសំ សុភាព ជាមន្ត្រីប៉ូលីសចរាចរណ៍មួយរូប នៅក្នុងចំណោមមន្ត្រីប៉ូលីសចរាចរណ៍ ដែលកំពុងតែបំពេញភារៈកិច្ច ដែលខិតខំបម្រើសណ្តាប់ធ្នាប់ចរាចរណ៍នៅក្នុងខេត្តកណ្តាល។*

**អ្នកនាំសារ៖** មុខរបរនៅក្នុងសង្គមមានច្រើន ប៉ុន្តែកញ្ញាបានសម្រេចចិត្តចាប់យក ឬជ្រើសរើសអាជីពជាមន្ត្រីប៉ូលីសចរាចរណ៍ ដូច្នេះសូមជួយជម្រាបជូនបន្តិចនូវ មូលហេតុអ្វីបានជាកញ្ញាសម្រេចចិត្ត ធ្វើជាមន្ត្រីប៉ូលីសចរាចរណ៍មួយរូបនៅក្នុងសង្គមយើង?

**សំ សុភាព៖** មូលហេតុដែលខ្ញុំបានសម្រេចចិត្តចូលបម្រើការងារជាមន្ត្រីប៉ូលីសចរាចរណ៍មួយរូបបែបនេះ គឺដោយសារតែមានការជម្រុញ និងលើកទឹកចិត្តពីគ្រួសារ និងដោយសារតែគ្រោះថ្នាក់ចរាចរណ៍ដែលគ្រួសារបានជួបផ្ទាល់តែម្តង។ នៅពេលដែលគ្រួសារបានជំរុញភ្លាម ខ្ញុំក៏ចាប់ផ្តើមនឹកឃើញ ហើយយល់ថា គ្រោះថ្នាក់ដែលគ្រួសាររបស់ខ្ញុំបានជួប គឺបានបង្កការលំបាកជាច្រើនកន្លងមក និងខ្ញុំមានចិត្តស្រលាញ់ ហើយចង់ក្លាយជាអ្នកបម្រើកិច្ចការនេះ។ ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នោះ បានធ្វើឲ្យជីវភាពគ្រួសារខ្ញុំធ្លាក់ចុះដុនដាប ហើយដោយសារគ្រោះថ្នាក់ចរាចរណ៍នោះ អីចឹងខ្ញុំក៏អត់មានការប្រកែកអ្វីទាំងអស់នៅពេលគ្រួសារផ្តល់យោបល់។ ម្យ៉ាងវិញទៀតខ្ញុំក៏បានឃើញនូវទិដ្ឋភាពជាក់ស្តែងក្នុងសង្គមរបស់យើងផ្ទាល់ ជាច្រើនអំពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍នេះ។ គ្រោះថ្នាក់ចរាចរណ៍ បានបង្កផលវិបាកច្រើនណាស់ ហើយក៏ជាបញ្ហាប្រឈមដែរ ដូច្នេះខ្ញុំក៏បាន សម្រេចចិត្តចូលបម្រើការងារនេះតែម្តងទៅ។

**អ្នកនាំសារ៖** តើសុភាពអាចជួយជម្រាបប្រាប់ពីជីវិតមុនពេល ធ្វើជាប៉ូលីសចរាចរណ៍មួយរូប ជូនយើងខ្ញុំបានជ្រាបផងបានទេ?

**សំ សុភាព៖** នៅមុនពេលចូលបម្រើការងារជាមន្ត្រីប៉ូលីសចរាចរណ៍ ខ្ញុំធ្លាប់ជាអ្នកគ្រូបង្រៀនភាសាអង់គ្លេសមួយរូប។ នៅក្នុងអំឡុងពេលនោះខ្ញុំចាំបានថា យើងជួបការលំបាកច្រើន ជាពិសេសនៅក្នុងអំឡុងពេលដែលគ្រួសារមានវិបត្តិដោយសារតែឪពុករបស់ខ្ញុំបានជួបគ្រោះថ្នាក់ចរាចរណ៍។ ជីវភាពគ្រួសារ យើងដុនដាបមែនទែន។ គ្រួសារត្រូវចំណាយប្រាក់យ៉ាងច្រើនដើម្បីរ៉ាប់រងថ្លៃព្យាបាល ហើយក្រោយមកម្តាយក៏មានបញ្ហា រីឯប្អូនប្រុសក៏ដូច្នេះទៀត គឺពិតជាពិបាកមែនទែន។

**អ្នកនាំសារ៖** អរគុណចំពោះចម្លើយ ប៉ុន្តែខ្ញុំសូមអនុញ្ញាតបន្ថែមសំណួរបន្តិចទៀតថា តើរាល់ថ្ងៃអ្នកបងចាប់ផ្តើមបំពេញការងារពីម៉ោងប៉ុន្មាន ហើយថាតើកញ្ញាបានជួបប្រទះផលវិបាកអ្វីខ្លះ នៅពេលចូលបម្រើការងារជាមន្ត្រីប៉ូលីសចរាចរណ៍?

**សំ សុភាព៖** យើងចាប់ផ្តើមធ្វើការពីម៉ោង ៤រសៀលទៅ រហូតដល់ម៉ោង ១១ យប់អធ្រាត្រ ជួនកាលអាចអូសបន្លាយយូរជាងនេះ ដោយបញ្ហាការងារពិបាក ហើយយើងក៏ជួបបញ្ហាប្រឈមច្រើនផងដែរ។ ជាមួយនឹងការងារនេះ ជួនកាលខ្ញុំត្រូវចប់ម៉ោងការងារនាម៉ោង១២ យប់អធ្រាត្រ ឬក៏ម៉ោងជិត ១ទៀបភ្លឺ ទើបយើងអាចបញ្ចប់ការងារ។ ហើយដូចជានៅថ្ងៃនេះខ្ញុំត្រូវទៅបំពេញភារៈកិច្ចដល់ពញាឮងណោះ ដូច្នេះទម្រាំខ្ញុំមកតាខ្មៅវិញវាឆ្ងាយ។ ការងារគឺវាឆ្ងាយ ដូច្នេះនេះជាផលលំបាករបស់ខ្ញុំ។ នៅក្នុងនាមជាស្ត្រីយើងលំបាកបន្តិចរឿងដើរគេង។ កាលចូលបម្រើការងារដំបូង យើងមានក្រុមការងារស្រីៗ៣នាក់ទាំងខ្ញុំ អីចឹងជួនខ្ញុំគេងជាមួយក្រុមការងារខ្ញុំ ដោយជួនកាលផ្ទះប្អូនស្រីមួយនេះ ជួនកាលផ្ទះប្អូនស្រីមួយនោះ។

**អ្នកនាំសារ៖** ចំពោះការងារនេះ ថាតើអ្នកនៅជុំវិញខ្លួន គេមានមតិយ៉ាងម៉េចខ្លះសម្រាប់អាជីពការងារជាមន្ត្រីប៉ូលីសចរាចរណ៍បែបនេះ?

**សំ សុភាព៖** អ្នកខ្លះថា ល្អហើយដែលយើងបានមានឱកាសចូលបម្រើការងារនេះ អ្នកខ្លះក៏ថា ទៅធ្វើស្អីទេអាមុខរបរ ដែលគេស្អប់អីចឹង រីឯអ្នកខ្លះទៀតគេថា ប្រជាជនភាគច្រើន អត់ចូលចិត្តអារឿងធ្វើប៉ូលីសចរាចរណ៍នោះទេ ហេតុផលដែលគាត់មិនចូលចិត្ត គឺពេលទៅជួបគាត់ ទី១គាត់ត្រូវបាត់បង់នូវថវិការដោយសារការផាកពិន័យ និយាយទៅគាត់អត់ចូលចិត្ត។

**អ្នកនាំសារ៖** បើការងារពិបាកអីចឹង ហេតុអ្វីបានជាកញ្ញា មិនលាឈប់ពីការងារនេះទៅ?

**សំ សុភាព៖** និយាយសរុបជារួមមក មូលហេតុដែលខ្ញុំពេញចិត្តនឹងការងារនេះ ដោយសារតែ ខ្ញុំអត់ចង់ឃើញមាន មនុស្សរបួស ស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍។ នៅពេលដែលយើងឃើញជីវិតជាក់ស្តែងរបស់អ្នកគ្រោះថ្នាក់ តើយើងមានអារម្មណ៍សង្វេកយ៉ាងណា។ ជួនកាលខ្ញុំឃើញជនរងគ្រោះ ស្លាប់នៅលើដងផ្លូវ ហើយជួនកាលគ្រាន់យើងឃើញសាកសពរបស់គាត់ យើងក៏អាណោចអាធម្មណាស់។ និយាយទៅខ្ញុំអត់ចង់ឃើញឈាម ដែលហូរ សម្លេងទ្រហោយំអំពីគ្រោះថ្នាក់ចរាចរណ៍ទៀត ទើបស្ម័គ្រចិត្ត និងស្រលាញ់ការងារនេះ។

*ដោយ សុផានិត*

### ទឹកចិត្តម្តាយ របស់មន្ត្រីប៉ូលីសចរាចរណ៍សាមញ្ញមួយរូបនៅកម្ពុជា

ជាទូទៅការងារដែលគេឃើញស្ត្រីនានា ច្រើនតែធ្វើការងារស្រាលនៅក្នុងម្លប់ នៅក្នុងការិយាល័យ ដោយឡែកការងារកញ្ញា សំ សុភាព បំពេញការងារក្រោមកំដៅ និងនៅតាមទីសាធារណៈ ប៉ុន្តែម្តាយរបស់កញ្ញានៅតែគាំទ្រ និងជំរុញកូន។

លោកស្រី សួង យ៉ង ជាស្ត្រីមេផ្ទះ អាយុ៥៤ ឆ្នាំ ដែលជាម្តាយរបស់បងស្រី សំ សុភាព បានថ្លែងគាំទ្រឲ្យកូនស្រីពេញទំហឹងនៅក្នុងការចាប់យកនូវមុខរបរជាមន្ត្រីប៉ូលីសចរាចរណ៍មួយរូបបែបនេះ ។

លោកស្រីបានឲ្យដឹងថា នេះគឺជាការងារដ៏ត្រឹមត្រូវ និងមានមោទនភាពមួយនៅក្នុងសង្គម។ គ្រួសារយើងគាំទ្រសុភាព។

លោកស្រីបានបញ្ជាក់ថា "ខ្ញុំមានអារម្មណ៍ថា សប្បាយចិត្តពេលដែលកូនស្រីរកបានការងារជាការងារមួយដែលធ្វើការទៅតាម ក្រឹតក្រមរបស់ច្បាប់ ការងារដែលនឹងបានជួយគេ ព្រោះថា នៅពេលដែលមានគ្រោះថ្នាក់អីចឹងទៅ បានជួយគេ ដូចបានបុណ្យយើងដែរ។

នៅក្នុងពេលបច្ចុប្បន្ននេះនៅតាមដងផ្លូវនានា គេសង្កេតឃើញមានមន្ត្រីប៉ូលីសចរាចរណ៍ជាច្រើន ដែលមានភារកិច្ច និងបេសកម្មរក្សាសណ្តាប់ធ្នាប់ចរាចរណ៍នៅកម្ពុជា ប៉ុន្តែគេកម្រឃើញមន្ត្រីប៉ូលីស ជាស្ត្រីច្រើនឡើយ ។

# ចំការផ្កាម្លិះជាច្រកផ្តល់ប្រភពចំណូលមួយដ៏ចំបងនៅកម្ពុជា

ផ្កាម្លិះដែលគេឃើញមានលក់នៅ តាមភ្លើងស្តុប តាមផ្សារ និងត្រូវបានប្រើប្រាស់នៅក្នុងពិធីផ្សេងៗ ទាំងនៅក្នុងពិធីបុណ្យសាសនាប្រពៃណី រហូតដល់ពិធីពាក់កម្រងផ្កានៅក្នុងកម្មវិធីផ្សេងៗនោះគឺ ភាគច្រើនមានប្រភពមកពី ភូមិព្រែកថ្មី នៅក្នុងរាជធានីភ្នំពេញនេះតែម្តង។

សព្វថ្ងៃនេះប្រជាពលរដ្ឋដែលរស់នៅភូមិព្រែកថ្មី ឃុំព្រែកថ្មី ខណ្ឌច្បារអំពៅ ជាង៩០%មានជីវភាពរស់នៅ ដោយពឹងផ្អែកលើរបរដាំនិងធ្វើចំការផ្កាម្លិះនេះតែម្តង។

ម្ចាស់ចំការ និងកម្មករនៅភូមិព្រែកថ្មីនេះ បានអះអាងថា ផ្កាម្លិះដែលឃើញនៅរាជធានីភ្នំពេញ ជាពិសេសនៅលើទីផ្សារភាគច្រើនបានយកចេញពីទីតាំងខាងលើ។

ផ្កាម្លិះដែលស្ថិតនៅភូមិព្រែកថ្មី ក្រៅពីចោលខ្លិនក្រអូបស្មើរតែពេញភូមិ តាំងពីព្រលឹមរហូតដល់ ពេលព្រលប់ វាគឺជាប្រភពចំណូលសំខាន់ណាស់សម្រាប់អ្នកភូមិ ដែលជាម្ចាស់ចំការ កម្មករបេះម្លិះ អ្នកចាក់ផ្កាម្លិះ អ្នកលក់ថ្នាំកសិកម្ម និងអាជីវករផ្ការនានានៅរាជធានីភ្នំពេញ។

កំពុងតែញាប់ដៃបេះផ្កាម្លិះ អ្នកស្រី វ៉ែន សាម៉ី ជាកម្មករបេះផ្កាម្លិះ ដែលមានទីលំនៅរស់នៅលើ មូលដ្ឋានខាងលើ បាននិយាយឲ្យដឹងថា អ្នកស្រី ប្រកបរបរនេះអស់រយៈពេល ១០ឆ្នាំមកហើយ ដោយរូបអ្នកស្រីអាចបេះផ្កាម្លិះ ចន្លោះពី២ទៅ៥គីឡូ-ក្រាម ក្នុងមួយថ្ងៃ អាស្រ័យនៅលើតម្រូវការ និងផ្ការម្លិះនៅក្នុងចំការដែលមាន។

អ្នកស្រីបានបន្ថែមថា ឈ្នួលបេះផ្កាម្លិះ ១គីឡូក្រាម គឺកំណត់យក ៥.០០០រៀល។

ជុំវិញការប្រកបរបរទទួលទានជាអ្នកបេះផ្កាម្លិះនេះ អ្នកស្រី ជា សុភឿន ដែលជា អ្នកភូមិ ដែលទទួលផលពីចំការផ្កាម្លិះមួយរូបទៀត បានថ្លែងថា ពីមុនធ្លាប់បេះផ្កាម្លិះ កណ្តាលថ្ងៃក្តៅដែរ ប៉ុន្តែពេលនេះគាត់បានប្តូរមកចាក់ផ្កាម្លិះក្នុងម្លប់ដោយសារបញ្ហាសុខភាព ។

អ្នកស្រីបានបញ្ជាក់ថា "ផ្កាម្លិះជួយសាងជីវភាពអ្នកភូមិភាគច្រើនឲ្យបានធូរធារ"។

អ្នកស្រី ជា សុភឿន បានបន្ថែមទៀតថា របរនេះងាយរកលុយដោយបេះរួចគេគិតគីឡូភ្លាមៗ។ ចំណាយពេលត្រឹម១ម៉ោង គឺគេអាចបេះបាន ២ទៅ៣ គីឡូក្រាម ហើយសម្រាប់ការចាក់ គឺរហូតដល់ល្ងាចទើបអាចរកបាន ២០.០០០ រៀល។

អ្នកស្រី សាន់ ដាណា ជាអ្នកដែលប្រកបរបរទទួលទានជុំវិញចំការផ្កាម្លិះមួយរូបទៀតបានថ្លែងថា ជាអ្នករស់នៅទីក្រុង តែអ្នកស្រីបានផ្ញើវាសនា លើផ្កាម្លិះនាភូមិព្រែកថ្មីជាង១០ឆ្នាំមកហើយ។

អ្នកស្រី សាន់ ដាណា បានទទួលស្គាល់ថា ផ្កាម្លិះមានទីផ្សារជានិច្ចបើទោះបីជាពេលខ្លះម្ចាស់ចម្ការរូបនេះត្រូវបង់ថ្លៃខាតឈ្នួលបេះ ដែលមិនចុះថ្លៃ កំឡុងពេលមិនសម្បូរផ្កា ហើយផ្កាម្លិះរាងមានតម្លៃទាបក៏ដោយ។

អ្នកស្រី បានបញ្ជាក់ថា ផ្កាម្លិះ មានការប្រកួតប្រជែងណាស់ ប៉ុន្តែវាជាផលិតផលដែលមានទីផ្សារជានិច្ច ក្រៅពីយកទៅកែច្នៃជាគ្រឿងផ្កាភ្ញី ផ្កាម្លិះក៏នៅមានទីផ្សារដែលគេអាចយកទៅកែច្នៃធ្វើជាតែផងដែរ។

លោកស្រីបានបញ្ជាក់ថា "បើទោះបីតម្លៃថ្លៃឬថោក ប៉ុន្តែផ្កាម្លិះគឺនៅតែមានទីផ្សារជានិច្ច"។



ចំការផ្កាម្លិះរបស់ប្រជាកសិករ នៅក្នុងសង្កាត់ព្រែកថ្មី។ ថតដោយ រិទ្ធី

លោក វង់ វុន ម្ចាស់ចម្ការក្បាលដី ១៨ ទល់នឹង ៣៥ម៉ែត្រ បានបង្ហើបប្រាប់ឲ្យដឹងថា ដំណាំផ្កាម្លិះត្រូវចំណាយថ្លៃថ្នាំ ដីសាំងបូមទឹកយ៉ាងទៀងទាត់ ទើបអាចទទួលបានផល។ លោកបានបន្តថា ក្នុងចម្ការ ផ្កាដែលមានផ្កាម្លិះជាង ៥០០ដើម លោកត្រូវបាញ់ថ្នាំ ៣ថ្ងៃម្តង ដោយការបាញ់ថ្នាំម្តងត្រូវចំណាយអស់ប្រហែលជា ៣០.០០០ រៀល ដើម្បីឲ្យផ្ការីកល្អទើបមានអ្នកទិញ។

បុរសដែលជាអ្នកលក់ថ្នាំកសិកម្ម ទើបបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រ ម្នាក់ក្នុងភូមិ លោកលុន គឹមសាយ បានថ្លែងដូចនេះថា អ្នកភូមិ ទិញថ្នាំគីមី ច្រើនជាងជីសរីរាង្គ ដើម្បីបាញ់សម្លាប់ សត្វល្អិតដង្កូវ នឹងផ្ទាំជំនួយដើម និងផ្កា ដែលអាចឃើញផលភ្លាមៗ រាល់ពេលដែរ លោកលក់ថ្នាំ លោក ធ្វើបានត្រឹមតែការណែនាំព្រមទាំងថែមជូន ម៉ាស់ដើម្បី ខ្ទាប់ច្រមុះសម្រាប់បន្ថយហានិភ័យនៅពេលបាញ់។

មេភូមិព្រែកថ្មី ឃុំព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ លោកជា តូ បានឲ្យដឹងថា ពលរដ្ឋប្រមានជា៩០% នៃពលរដ្ឋ ១៩៨គ្រួសារ នៃភូមិព្រែកថ្មីមួយមានអាជីព និងជាអ្នកទទួលផលពីដំណាំចំការផ្កាម្លិះនេះ ដោយសារដំណាំនេះផ្តល់ថវិការប្រចាំថ្ងៃ។

ជាអ្នកលក់ផ្កាម្លិះ នៅផ្សារធំថ្មីរាជ-ធានីភ្នំពេញ អ្នកស្រី ផៃ នរិទ្ធ បានថ្លែងថា អ្នកស្រី ត្រូវប្រឈមនឹង អាកាសធាតុក្តៅមេឃភ្លៀង ការព្រមានពីកងសណ្តាប់ធ្នាប់រាជធានីភ្នំពេញ ជាមួយនឹង ការប្រមាថ ពីសំណាក់ពលរដ្ឋមួយចំនួនដែលមិនយល់ពីតម្លៃនៃការងារ ដែលបានប្រដូចអ្នកលក់ផ្កាតាមផ្សារ តាមស្តុប ទៅនឹងអ្នកសុំទានតាមផ្លូវ ប៉ុន្តែជាមួយនឹងផ្ការម្លិះនេះ អ្នកស្រីអាចរកចំណូលបានពី ៤០.០០០ ទៅ ៥០.០០០ រៀលក្នុងមួយថ្ងៃ។

លោកជា តូ បានឲ្យដឹងថា ជុំវិញដំណាំនេះកន្លងមក ក៏ធ្លាប់មានក្រុមហ៊ុនចុះមកសិក្សា ពីលទ្ធភាពផលិតទឹកអប់ ក្លិនផ្កាម្លិះដែរ។

រហូតមកដល់ពេលនេះ ផលិតផលដែលគេឃើញពីចំការផ្កាម្លិះ គឺមានដូចជា កម្រងផ្កាម្លិះ សម្រាប់យកទៅគោរពបូជា ព្រះពុទ្ធរូប វត្ថុសាកសិទ្ធ ជូនបុគ្គលសំខាន់ៗ ឬដាក់តាំងក្នុងឡានសម្រាប់ស្រង់យកពិដោរក្រអូបរបស់វាជាដើម ចំណែកតម្លៃរបស់វាត្រូវបានគេលក់ទៅតាម ភួង តាមកម្រង តែបើថ្លឹងគីឡូ គឺ ចន្លោះពី ១០០.០០០ រៀល ទៅដល់ ១៥០.០០០ រៀល។

ក្រៅពីផ្កាម្លិះ កសិករកម្ពុជាគឺនៅមានដាំផ្កាមួយចំនួនទៀត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ផ្កាម្លិះនៅតែជា ផ្កាមួយប្រភេទដែលមានទីផ្សារ និង មានតម្រូវការខ្លាំងជាងគេ ។

*ដោយ អរិយបុត្រ*



សកម្មភាពប្រជាកសិករកំពុងចាក់ផ្កាម្លិះធ្វើជាភួង នៅក្នុងសង្កាត់ព្រែកថ្មី។ ថតដោយ រិទ្ធី

## ប្រមុខរដ្ឋាភិបាលប្រាប់អត្តពលិកឲ្យត្រៀមខ្លួនឲ្យហើយសម្រាប់ព្រឹត្តិការណ៍កីឡាស៊ីហ្គេមឆ្នាំ២០២៣

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីបាយសាមគ្គីនៅកោះពេជ្រ និងសម្ពោធពហុកីឡដ្ឋានថ្មី មរតកតេជោ នៅដើមខែមេសាទីអាផ្ទាធរ និងអ្នកដែលពាក់ព័ន្ធជាពិសេសគឺអត្តពលិក ឲ្យត្រៀមខ្លួនសម្រាប់ព្រឹត្តិការណ៍ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះកីឡាស៊ីហ្គេមឆ្នាំ២០២៣។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានថ្លែងថា ពេលវេលាវានៅប្រមាណជា៦ឆ្នាំទៀត ប៉ុន្តែវាក៏មិនជាយូរដែរ ដូច្នេះការត្រៀមខ្លួនគឺជារឿងដែលសំខាន់នឹងយកចិត្តទុកដាក់។

សម្តេចតេជោហ៊ុន សែន បានបញ្ជាក់ថា ឆ្នាំនេះប្រទេសម៉ាឡេស៊ីធ្វើជាម្ចាស់ផ្ទះ ដល់ទៅឆ្នាំ២០១៩ គឺហ្វីលីពីន ហើយនៅឆ្នាំ២០២១ គឺនៅវៀតណាម បន្ទាប់មក គឺកម្ពុជាហើយ ។

តាមការគ្រោងទុកព្រឹត្តិការណ៍កីឡាថ្នាក់តំបន់នេះ កម្ពុជាគ្រោងនឹងរៀបចំឡើងនៅក្នុងរង្វង់ពីថ្ងៃទី១ ដល់១៥ ខែធ្នូ ឆ្នាំ២០២៣ ដោយព្រឹត្តិការណ៍នេះកើតឡើងនៅរាជធានីភ្នំពេញ នៅកំពត នៅកែប នៅតាកែង សៀមរាប បាត់ដំបង និងខេត្តកំពង់ចាម។

នៅក្នុងព្រឹត្តិការណ៍រយៈពេល ២សប្តាហ៍នេះកម្ពុជារំពឹងថា នឹងទាក់ទាញគណប្រតិភូប្រមាណជា១០.០០០ពីអាស៊ាន ក្នុងនោះអត្តពលិកមានប្រមាណជា៧.០០០នាក់។

គួររំឭកថា ផែនការមេឆ្ពោះទៅរកការធ្វើជាម្ចាស់ផ្ទះនៃកីឡាស៊ីហ្គេមនេះ គឺបានទទួលការអនុម័ត ពីគណរដ្ឋមន្ត្រីកម្ពុជារួចហើយកាលពីខែមេសា ឆ្នាំ២០១៦ ដោយតាមការរំពឹងទុក កម្ពុជា គ្រោងនឹងខិតខំឲ្យបានមេដាយមាសប្រមាណជា ៣០ភាគរយ នៃមេដាយមានសរុប ៣០០ ពីព្រឹត្តិការណ៍ កីឡានេះ។

## អាជ្ញាធរអូស្ត្រាលីរឹបអូសគ្រឿងញៀន ៩០៣គីឡូក្រាម

ក្រុមមន្ត្រីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសអូស្ត្រាលីបាននិយាយនៅថ្ងៃទី៥ ខែមេសាថា សមត្ថកិច្ចប៉ូលិសនៅក្នុងប្រទេសនេះ បានរឹបអូសនូវគ្រឿងញៀនមេតំហ្វេតាមីនក្រាមដ៏ច្រើនដែលមានតម្លៃជាច្រើនរយលានដុល្លារ។

ប្រភពដដែលបានត្រូវសារព័ត៌មានរបស់អូស្ត្រាលីដកស្រង់ថា គ្រឿងញៀនដែលរឹបអូសបានមានចំនួនរហូតដល់ ៩០៣ គីឡូក្រាម ។

ប្រភពដដែលបន្តថា គ្រឿងញៀនទាំងនោះ ត្រូវបានលួចនាំចូលពីប្រទេសចិន ដោយលាក់ទុកនៅខាងក្នុងក្តារក្រាលជាច្រើនបន្ទះ។ នេះជាការចាប់បានគ្រឿងញៀនខុសច្បាប់ដ៏ច្រើនបំផុតនៅប្រទេសអូស្ត្រាលី ដែលអាជ្ញាធររឹបអូសបាន។

ក្រុមមន្ត្រីច្បាប់ បានវាយតម្លៃថា គ្រឿងញៀនទាំងនេះ ដែលភាគច្រើន ត្រូវបានរកឃើញនៅឃ្លាំងដាក់អីវ៉ាន់មួយនៅទីក្រុងមែលប៊ន ដោយវាមានតម្លៃប្រមាណជាជាង ៦៨០លានដុល្លារអាមេរិក។

ប៉ូលិសបាននិយាយថា បុរសជនជាតិអូស្រាលី២នាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទជួញដូរគ្រឿងញៀន ហើយពួកគេអាចជាប់គុកអស់មួយជីវិត បើសិនត្រូវបានកាត់ទោសឱ្យជាប់ទោសនោះ។

## ថ្លៃទឹកត្រូវបាននាយករដ្ឋមន្ត្រីផ្តល់អនុសាសន៍ឲ្យបញ្ចុះ

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុន សែន បានជម្រុញឲ្យរដ្ឋករទឹករាជធានីភ្នំពេញពិនិត្យការបញ្ចុះតម្លៃទឹកដើម្បីជួយសម្រួលការលំបាករបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ។

នេះគឺជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍៣ ដែលសម្តេចតេជោ ហ៊ុន សែន បានផ្តល់នៅក្នុងឱកាសអញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតជំហានទី២ នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ដែលមានតម្លៃជាង ៦០លានដុល្លារ ។

ក្រៅពីនោះសម្តេចតេជោ ហ៊ុន សែន ក៏បានជំរុញឲ្យបង្កើនការតបណ្តាញផ្គត់ផ្គង់ទឹកជូនដល់ប្រជាពលរដ្ឋ ដែលមិនទាន់ទទួលបានបណ្តាញទឹកស្អាត និង បង្កើនទុនទិញយកបណ្តាញទឹកដែលបានផ្តល់ជូនឯកជនវិនិយោគយកមកគ្រប់គ្រង នឹងផ្គត់ផ្គង់ឡើងវិញ។

យោងទៅតាមគេហទំព័ររបស់រដ្ឋករទឹកស្វ័យយ័តរាជធានីភ្នំពេញ បានឲ្យដឹងថា កាលពីឆ្នាំ២០១៦ រដ្ឋករទឹកបានតភ្ជាប់បណ្តាញ និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋសរុបចំនួន៣០៩.៣០០ ដោយនៅក្នុងនោះតម្លៃគឺចាប់ពី ៥៥០រៀល ទៅដល់ ១.៤៥០រៀល នៅក្នុងមួយម៉ែត្រគូបទៅតាមទំហំប្រើប្រាស់ ប៉ុន្តែតម្លៃដែលប្រជាពលរដ្ឋប្រើប្រាស់ គឺនៅក្នុងតម្លៃជាមធ្យមគឺ៧៧០រៀលនៅក្នុងមួយម៉ែត្រគូប។

## ត្រីមាសទី១ អ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក មានចំនួន ៤៩២ នាក់

រយៈពេល៣ខែ គិតពីខែមករា ដល់ខែមីនា ឆ្នាំ២០១៧ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកបានកើតឡើង ៩៨៩លើកបណ្តាលឲ្យស្លាប់សរុប ៤៩២លើក និងរបួសសរុបចំនួន ១៤៦៨នាក់ ពោលគឺថយចុះបន្តិចបន្តួច ប៉ុណ្ណោះធៀបនឹងរយៈពេលដដែលកាលពីឆ្នាំទៅ។

នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការនគរបាលជាតិបានបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅខែមករា កើតឡើង ៣៧៩ លើក ស្លាប់ ១៨៥ នាក់ និងរបួស ៥៧៤ នាក់។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅខែកុម្ភៈ កើតឡើង ២៨៤លើក ស្លាប់ ១៤០នាក់ និងរបួស៤១៨នាក់។ រីឯគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ប្រចាំខែមីនា ឆ្នាំ ២០១៧ នៅទូទាំងប្រទេស បានកើតឡើង ៣២៦លើក ស្លាប់ ១៦៧នាក់ និងរបួសសរុប ៤៧៦ នាក់។

គួររំឭកថា កាលពីឆ្នាំ២០១៦ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅទូទាំងប្រទេស បានសម្លាប់មនុស្ស ១.៧១៧នាក់ និងរបួស ៦.៦០៧នាក់។ ក្នុងនោះ នៅខែមករា ឆ្នាំ២០១៦ មានអ្នកស្លាប់ច្រើនជាងគេ រហូតដល់១៨៨នាក់ ហើយកាលពីឆ្នាំ ២០១៥ គ្រោះថ្នាក់ចរាចរណ៍នៅទូទាំងប្រទេស សម្លាប់មនុស្ស ២.២៦៥ នាក់ និងអ្នករបួស ៧.៥១០ នាក់។

ប្រភពដដែលបានឲ្យដឹងថា មូលហេតុចំបងនៃគ្រោះថ្នាក់ចរាចរណ៍ទាំងនេះ គឺបើកបរហួសល្បឿនកំណត់ និងគ្រឿងស្រវឹង ។

## រុស្ស៊ីបញ្ជូននាវាមុជទឹកដ៏ធំបំផុតទៅកាន់សមុទ្របាល់ទិក

កងកម្លាំងរុស្ស៊ីបានបង្ហាញសាច់ដុំយោធាជាថ្មីជាមួយនឹងសព្វាវុធនុយក្លេអ៊ែររបស់ខ្លួនតាមរយៈការបញ្ជូននាវាមុជទឹកដ៏ធំបំផុតនៅលើពិភពលោករបស់ខ្លួន។

ទីភ្នាក់ងារព័ត៌មានបរទេសបានរាយការណ៍ថា នាវានោះ គឺជានាវាទំនើបបំពាក់អាវុធក៏ទំនើបចំនួន ២០០គ្រាប់ ដោយរួមទាំងមីស៊ីលនុយក្លេអ៊ែរចំនួន២០ ទៅកាន់សមុទ្របាល់ទិក។

នាវាមុជទឹកនេះត្រូវបានគេស្គាល់ថា ជានាវា ឌីមីទ្រី ដុនស្កូយ ហើយ គ្រោងចាកចេញពីសមុទ្រ ស ដោយបើកតម្រង់ទៅក្បែរប្រទេសន័រវែសនិងដាណឺម៉ាកនៅក្នុងតំបន់មួយ ដែលក្រុមមន្ត្រីរុស្ស៊ីហៅថា ជាតំបន់របស់កងទ័ពអង្គការណាតូនោះ។

នាវារុស្ស៊ីដ៏ធំនេះ មានបណ្តោយប្រវែងជាង១៦៦ម៉ែត្រ និងបំពាក់អាវុធជាច្រើន ហើយវាជានាវា មួយដ៏ធំក្នុងចំណោមនាវាជាច្រើននៃសម័យសង្គ្រាមត្រជាក់។ វាជានាវាអាចស្ថិតនៅបាតសមុទ្ររហូតដល់ទៅជាង១២០ថ្ងៃឯណោះ និងមានគ្រាប់បែកប្រឆាំងនាវាមុជទឹកជាច្រើនគ្រាប់។ នាវានេះមានក្រុមនាវិកចំនួន១៦០នាក់។ នាវានេះ ត្រូវបានដាក់ឱ្យដំណើរការដោយកងទ័ពសូវៀតនៅទសវត្សរ៍ឆ្នាំ១៩៨០។

## ប្រធានាធិបតីហ្វីលីពីនបណ្តេញរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពីតំណែង

ប្រធានាធិបតីហ្វីលីពីន លោក រ៉ូឌ្រីហ្គោ ឌូតឺតេ បានបណ្តេញរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់លោក ចេញពីតំណែង ។

លោក អ៊ីណេស្តូ អាបែលឡា អ្នកនាំពាក្យប្រធានាធិបតី បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា "លោក រ៉ូឌ្រីហ្គោ ឌូតឺតេ បានដក លោក អ៊ីស្មាអែល ស៊ូណូ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពីតំណែង ដោយលើកឡើងអំពីការបាត់បង់ការជឿជាក់និងទំនុកចិត្ត"។ លោកបានបន្ថែមថា ការដកតំណែងនេះគឺជាការព្រមានដល់ក្រុមមន្ត្រីផ្សេងៗទៀត។

មូលហេតុនៃការបណ្តេញចេញនេះ ត្រូវបានសារព័ត៌មានចុះផ្សាយថា គឺដោយសារតែលោកអស់ការជឿជាក់និងការបាត់បង់ទំនុកចិត្ត ដោយសារតែការចោទប្រកាន់ពីបទពាក់ព័ន្ធនឹងអំពើពុករលួយ។

លោក រ៉ូឌ្រីហ្គោ ឌូតឺតេ បានឡើងកាន់អំណាចអស់រយៈពេល១០ខែកន្លងមកហើយ ដោយការដឹកនាំរបស់លោក គឺប្រើកណ្តាប់ដៃដែកប្រឆាំងនឹងបទល្មើសគ្រឿងញៀន និងឧក្រិដ្ឋកម្ម ។

លោក រ៉ូឌ្រីហ្គោ ឌូតឺតេ ធ្លាប់បានអះអាងថា ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ឧក្រិដ្ឋកម្ម និងអំពើពុករលួយដើម្បីកសាងសេដ្ឋកិច្ចជាតិគឺជា គោលនយោបាយរបស់លោក ។

កន្លងមក លោកបានដកមន្ត្រីអសកម្មរាប់សិបនាក់ មន្ត្រីអន្តោប្រវេសន៍ជាន់ខ្ពស់ ២នាក់និងអតីតអ្នកនាំពាក្យម្នាក់ពីតំណែង ដោយសារបញ្ហាពុករលួយនេះ ។

# អាណាព្យាបាលជំរុញឲ្យលោកគ្រូ និងអ្នកគ្រូលុ

ក្រោយពេលដែលសាធារណជនទូទៅដឹងថា លោកគ្រូនិងអ្នកគ្រូកំពុងតែទទួលបាននូវការតម្លើង ប្រាក់បៀវត្សរ៍ប្រចាំខែ នោះអាណាព្យាបាលសិស្សភាគច្រើនបានសំដែងនូវការអបអរ ប៉ុន្តែបាន សំណូមពរឲ្យលោកគ្រូនិងអ្នកគ្រូយកចិត្តទុកដាក់នៅក្នុងការពង្រឹងគុណភាពអប់រំមួយកម្រិតថែមទៀត។

លោក វិញ តុលា ជាអាណាព្យាបាលនៃកុមារពីររូបដែលកំពុងតែសិក្សានៅសាលាបឋមសិក្សាមួយ នៅក្នុងទីក្រុងភ្នំពេញបានថ្លែងថា ប្រាក់ខែគ្រូបង្រៀនឡើងទៀត ហើយ ដូច្នេះសង្ឃឹមថា បាតុភាពអវិជ្ជមាននៅក្នុងវិស័យអប់រំនឹងកាត់បន្ថយ។

លោកបានថ្លែងថា តាមព័ត៌មានកន្លងមក ដើម្បីជួយលើកកម្ពស់ដល់ជីវភាពនិងការរស់នៅរបស់មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដំឡើងប្រាក់បៀវត្សរ៍ ដូច្នេះយើងសង្ឃឹមថា បាតុភាពអសកម្ម និងអវិជ្ជមាននៅក្នុង វិស័យការងារនិងមានការកែលំអរជាពិសេសគឺស្ថាប័នអប់រំ។

លោក ជិន កេតសុវណ្ណ ជាបិតានៃកុមារមួយរូបដែលកំពុងតែសិក្សានៅកម្រិតអនុវិទ្យាល័យមួយរូបបានឲ្យដឹង ថា វាគឺជារឿងល្អ ដែលរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សជូនគ្រូបង្រៀន ប៉ុន្តែទន្ទឹមនឹងការបង្រៀននេះ ក្រសួងអប់រំគួរតែយកចិត្តទុកដាក់ទៅលើការពង្រឹងគុណភាពនៅក្នុងម៉ោងសិក្សារដ្ឋ ការកាត់បន្ថយការលក់ក្រដាស់មេរៀន ...។ល។

លោកបានបន្តថា លោកមិនបានដឹងច្បាស់ថា វាយ៉ាងណានោះឲ្យវាប្រាកដទេ ប៉ុន្តែតាមដែលកូនរបស់លោកបាននិយាយគឺថា មួយថ្ងៃគេទារលុយច្រើន ដោយលុយនោះគេប្រាប់ថា រៀនគួរ ទិញក្រដាសមេរៀនជាដើម។

លោកបានបញ្ជាក់ថា "តាមដែលកូនខ្ញុំគេបានទារលុយគឺថា មួយថ្ងៃៗ គឺមិនក្រោម៥០០០ រៀលទេ ហើយមានថ្ងៃខ្លះ គឺឡើងដល់ ១០.០០០រៀលក៏មានដែរ "។



សិស្សានុសិស្ស នៅអនុវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី វត្តភ្នំ។ ថតដោយ លីហៀង

លោកបានបន្តថា កាលនៅបឋមសិក្សាកូនរបស់លោកដូចជាមិនចំណាយច្រើនទេ គឺឃើញអ្នកគ្រូគាត់សុំបង់ត្រឹមប្រាក់សម្រាប់ទ្រទ្រង់អគ្គីសនី ថ្លៃបើកកង្ហារនៅសាលាមួយសប្តាហ៍ពី ៥០០ទៅ ១០០០ រៀលប៉ុណ្ណោះ ហើយនឹងថ្លៃជប់លៀងម្តងម្កាលតែប៉ុណ្ណោះ ប៉ុន្តែដល់ឡើងពីបឋមការចាយវាយដូចជារៀងចុះបន្តិច។

លោកហៀង ភីរុណ ជាអ្នកបើកម៉ូតូរឺម៉កដឹកភ្ញៀវទេសចរមួយរូបបានឲ្យដឹងថា សម្រាប់អ្នកដែលមានកូនសិក្សានៅជនបទដូចជារូបលោក សោហ៊ុយនៅក្នុងការទំនុកបម្រុងការសិក្សារបស់កូន គឺមិនជាចោទប៉ុន្មានទេលោកគ្រូអ្នកគ្រូទៀតសោតក៏មិនសូវជាទាថ្ងៃនេះ ឬថ្ងៃនោះអីដែរ ប៉ុន្តែអ្វីដែលលោកកត់សំគាល់ គឺវាដូចជារយឹករយាកបន្តិចរឿងម៉ោងពេល។

លោកបានបញ្ជាក់ថា "រឿងលុយរឿងអីគាត់(លោកគ្រូ ឬអ្នកគ្រូ) ដូចជាមិនដែលទារទេ បើទារកូនខ្ញុំគេមកសុំម៉ែវា ហើយតែឧស្សាហ៍ឃើញកូនវានៅផ្ទះ ហើយពេលខ្ញុំសួរ វាប្រាប់ថា អ្នកគ្រូជាប់ទៅ ទិញឥវ៉ាន់នៅភ្នំពេញ"។

លោកបានបន្តថា ភាគច្រើននៃជីវភាពលោកគ្រូនិងអ្នកគ្រូនៅតាមស្រុកស្រែចំការគឺអីចឹង ដោយក្រៅពីបង្រៀនគាត់មានមុខរបរជាអ្នកលក់ចាប់ហួយ ធ្វើនេះធ្វើនោះជាដើម ដោយសារតែគាត់បង្រៀនតែមួយពេល។

ជុំវិញបញ្ហានេះលោកវិញ តុលាក៏បានកត់សំគាល់បែបនេះថា នេះសឹងតែជារឿងទូទៅនៅក្នុងវិស័យអប់រំ នៅតំបន់ជនបទនៅកម្ពុជា។

លោកបានបន្តថា នៅពេលដែលលោកបានចុះទៅធ្វើការតាមខេត្ត នាតំបន់ជន

### ប្រមុខរដ្ឋាភិបាលកម្ពុជាជំរុញឱ្យពង្រឹងគុណភាពនៃវិស័យអប់រំ

*សម្តេចតេជោហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញអំពីការកោតសរសើចំពោះកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ប៉ុន្តែសម្តេចនៅតែបន្តជំរុញឱ្យក្រសួង និងសាធារណជនចូលរួមទាំងអស់គ្នាដើម្បីលើកកំពស់វិស័យនេះបន្ថែមទៀត។*

*សម្តេចតេជោ ហ៊ុន សែន បានបង្ហាញការសង្ឃឹមថាអ្វីដែលជាការប្រមាថនិង ការម៉ាក់ងាយថាសញ្ញាបត្រនៅកម្ពុជាគ្មានតម្លៃ និងត្រូវលុបបំបាត់តាមរយៈការខិតខំពង្រឹងគុណភាពរបស់វិស័យអប់រំនៅកម្ពុជា។*

*កាលពីពេលថ្មីៗនេះ សម្តេចតេជោ ហ៊ុន សែន បានថ្លែងប្រាប់ គរុនិស្សិតចំនួន ១.២៥៦ នាក់ ដែលនឹងត្រូវបែងចែកទៅធ្វើជាគ្រូបង្រៀននៅទូទាំងប្រទេសថា "ខ្ញុំសង្ឃឹមថាអ្វីដែលជាការការម៉ាក់ងាយ និងការប្រមាថ ថាសញ្ញាបត្រនៅកម្ពុជាគ្មានតម្លៃ និងត្រូវលុបបំបាត់តាមរយៈការខិតខំពង្រឹងគុណភាពរបស់វិស័យអប់រំនៅយើង ព្រោះយើងទទួលការប្រមាថយ៉ាងធ្ងន់"។*

*សម្តេចបានបន្តថា "មិនប្រាកដទេណាថាអ្នករៀននៅក្រៅប្រទេសពូកែជាងអ្នករៀននៅក្នុងប្រទេស ទទួលស្គាល់អ្នកឯងចេះភាសាល្អតែឆ្កែក៏វាចេះភាសាដែរ... វាទៅនៅស្រុកណាវាចេះភាសាស្រុកហ្នឹង។ ឆ្កែនៅបារាំងវាចេះបារាំង,ឆ្កែនៅអង់គ្លេសវាចេះអង់គ្លេស ឆ្កែនៅថៃវាចេះថៃ ឆ្កែនៅវៀតណាមវាចេះវៀតណាម ដូចនេះឆ្កែនៅខ្មែរគឺវាចេះខ្មែរដូចនេះកុំឆ្ងល់។ ប៉ុន្តែ បញ្ហាចំណេះដឹងរបស់មនុស្សវាមិនស្ថិតនៅលើចេះភាសាមួយមុខនោះទេ គឺវាពឹងទៅលើសមត្ថភាព និងចំណេះដឹង"។*

# រ បំបាត់បាតុភាពអវិជ្ជមាននៅតាមសាលារៀន



បទមួយចំនួន នៅក្នុងប្រទេស ស្ថានភាពនៅតាមសាលារៀននីមួយៗ គឺបែបនេះ។ លោកបានឲ្យដឹងថា នេះមិនមែនជារឿងថ្មីទេ វាគឺជាករណីដែលកើតសឹងតែគ្រប់កន្លែងនៅជនបទ។

លោកបញ្ជាក់ថា "នៅសាលានៅឯជន-បទគឺថា រឿងចូលយឺត ចេញមុនគឺជាទូ-ទៅហើយ មានករណីខ្លះលោកគ្រូនិងអ្នកគ្រូឧស្សាហ៍ឈប់ផងដែរ ដោយសារតែជីវភាព ប៉ុន្តែជាមួយនឹងគោលនយោបាយការតម្លើងប្រាក់បៀវត្សរ៍របស់រដ្ឋាភិបាលយើងសង្ឃឹមថា លោកគ្រូនិងអ្នកគ្រូកាត់បន្ថយចំណុចអសកម្មទាំងនេះ។

លោកស្រី ដាញ់ ម៉ូនិច ដែលអះអាងថា គឺជាអតីតអ្នកគ្រូចូលនិវត្តន៍មួយរូបបានមានប្រសាសន៍ថា រឿងលក់ក្រដាស រឿងបង្រៀនគួរ រឿងចេញចូលបង្រៀនយឺ រឿងអវត្តមានម្តងម្កាល សូមកុំបន្ទោសលោកគ្រូនិងអ្នកគ្រូបង្រៀនអី ដោយសារតែនេះគឺជារឿងជីវភាព។

លោកស្រីបានបន្តថា រឿងអសកម្មទាំងនេះ មិនមែនជារឿងថ្មីទេ ហើយគេក៏និយាយច្រើនណាស់មកហើយដែរ ប៉ុន្តែសូមកុំបន្ទោស លោកគ្រូនិងអ្នកគ្រូអី។ លោកស្រីបានបន្តថា លោកស្រីយល់ពីអារម្មណ៍នេះ ដោយលោកស្រី ក៏ធ្លាប់ធ្វើជាគ្រូបង្រៀន ហើយឥឡូវកំពុងតែធ្វើជាអាណាព្យាបាលចៅ ពីរនាក់ដែលកំពុងតែសិក្សាដូចគ្នា។

លោកស្រីបានបញ្ជាក់ថា "នៅក្នុងនាមជាអតីតគ្រូបង្រៀនមួយរូប ខ្ញុំយល់ពីអារម្មណ៍នេះ ហើយឥឡូវ ខ្ញុំមិនបន្ទោសទេ"។

លោកស្រីបានបញ្ជាក់ទៀតថា "រឿងឡើងប្រាក់ខែ ខ្ញុំជួយអរពួកគេ ប៉ុន្តែកុំថាឡើយឡើង ១០០.០០០រៀល ទោះឡើង ២០០.០០០ ក៏មិនអាចជួយជីវភាពបានទាំងស្រុងដែរឡើងប៉ុណ្ណេះ គឺគ្រាន់តែជួយសម្រួលខ្លះប៉ុណ្ណោះ"។ នៅក្នុងដំណើរការកំណែទម្រង់រឿងប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធនេះ គ្រូបង្រៀនដែលមានចំនួនប្រមាណជា ជាង ១០ម៉ឺននាក់ គឺហាក់ទទួលបានការយកចិត្ត ទុកដាក់ខ្ពស់ ហើយដោយឡែកទំហំប្រាក់បៀវត្សរ៍នោះក៏ទទួលបានការតម្លើងច្រើន។

តាមការប្រកាសរបស់ប្រមុខរដ្ឋាភិបាលកម្ពុជាបានឲ្យដឹងថា ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧ ពោល គឺមុនបុណ្យចូលឆ្នាំខ្មែរមកដល់ រាជរដ្ឋាភិបាលបានសម្រេចដំឡើងប្រាក់បំណាច់មុខងារ បន្ថែមលើប្រាក់បៀវត្សរ៍គោលដល់មន្ត្រីរាជការនិងកងកម្លាំងទូទៅ ប៉ុន្តែចំពោះគ្រូបង្រៀនបន្ទាប់ពីបន្ថែមប្រាក់បំណាច់មុខងារ លើប្រាក់បៀវត្សរ៍គោល ធ្វើឲ្យគ្រូបង្រៀនកម្រិតទាបបំផុត មានប្រាក់ខែ៩៥៣,៥០០រៀល និងខ្ពស់បំផុតចំនួន២,២៦៥,០០០រៀល ដោយប្រាក់ខែនេះមិនទាន់បូក បញ្ចូលប្រាក់វិភាជន៍គ្រួសារ (ប្រសិនបើគ្រូបង្រៀនមានប្រពន្ធនិងកូន) និងប្រាក់តំបន់សម្រាប់វិស័យអប់រំ នៅឡើយនោះទេ។

កាលពីពេលថ្មីៗនេះលោកយក់ ប៊ុនណា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមុខងារសាធារណៈ បានថ្លែងប្រាប់សារព័ត៌-មាននៅក្នុងស្រុកថា ចាប់ពីខែមេសា ឆ្នាំ ២០១៧ តទៅប្រាក់ខែគ្រូបង្រៀន នឹងត្រូវឡើងដូចខាងក្រោម៖

បៀវត្សខ្ពស់បំផុត សម្រាប់អប់រំក្នុងមុខតំណែង៖

*នាយកវិទ្យាស្ថានជាតិ ទទួលបាន ២,២៦៥,០០០រៀល។

* គ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅមហាវិទ្យាល័យទទួលបាន១,៥៩៥,០០០ រៀល។

*គ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅវិទ្យាល័យទទួលបាន១,៥១៥,០០០រៀល។

*នាយកវិទ្យាល័យ ទទួលបាន ១,៧០៥,០០០រៀល។

*គ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ ទទួលបាន ១,៣៥៣,០០០រៀល។

* នាយកអនុវិទ្យាល័យទទួលបាន ១,៥១៣,០០០រៀល។

*គ្រូបង្រៀនកម្រិតបឋមបង្រៀននៅបឋមសិក្សា និងមត្តេយ្យសិក្សា ទទួលបាន ១,១៩១,០០០រៀល។

*នាយកបឋមសិក្សា ទទួលបាន ១,៣៣១,០០០រៀល។

* នាយកមត្តេយ្យសិក្សា ទទួលបាន ១,៣១១,០០០រៀល។

បៀវត្សទាបបំផុតរបស់គ្រូបង្រៀន ទទួលបាន ៩៥៣,៥០០រៀល។

មន្ត្រីអ្នកនាំពាក្យរូបនេះ បានបញ្ជាក់ទៀតថា ប្រាក់បៀវត្សរ៍ខាងលើនេះ គិតបញ្ចូលតែ បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ នៅមិនទាន់បូកបន្ថែមអាចជាប្រាក់វិភាជន៍គ្រួសារ ដែលប្រពន្ធទទួលបាន ១៥,០០០រៀល, កូនម្នាក់ទទួលបាន១០,០០០រៀល និងប្រាក់តំបន់ដែលចែកចេញជា៣ប្រភេទទៅតាមជិត និងឆ្ងាយដែលមានចំនួន ៨០,០០០ រៀលទៅ ១០០,០០០រៀល និងខ្ពស់បំផុត ១២០,០០០រៀល។

ទាក់ទិននឹងការតម្លើងនេះលោក ជិន កេតសុវណ្ណ បានបញ្ជាក់បន្ថែមថា ការតម្លើងនេះគឺមិនច្រើនប៉ុន្មានទេ ប៉ុន្តែវាគ្រាន់បើដែរ ដូច្នេះខ្ញុំសង្ឃឹមថា លោកគ្រូនិងអ្នកគ្រូ នឹងចូលរួមពង្រឹងគុណភាពបង្រៀនបង្កើនការសិក្សាស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ សម្រាប់ឲ្យសិស្សឆាប់ចេះឆាប់ចាប់បាន។

លោកបានបន្តថា "ខ្ញុំដឹងថាប្រាក់បៀវត្សរ៍ដែលតម្លើងនេះ គឺពិតជាមិនទាន់ឆ្លើយតបនឹងតម្រូវការជីវភាពមួយដែលរស់នៅសមរម្យគ្រប់គ្រាន់បរិបូរណ៍នៅឡើយទេ ប៉ុន្តែយ៉ាងហោចណាស់ក៏អាចជួយសម្រាលនូវតម្រូវការចាំបាច់មួយចំនួននៅក្នុងជីវភាពបានដែរ ដូច្នេះខ្ញុំក៏សង្ឃឹមថា លោកគ្រូនិងអ្នកគ្រូទាំងអស់នឹងយល់ ហើយបន្តខិតខំបណ្តុះបណ្តាលកូនខ្មែរយើងបន្តទៅទៀត ដើម្បីជាទុននិងជាការជួយកសាងនូវធនធានមនុស្សមួយសម្រាប់តម្រូវការនៅក្នុងសង្គមនៅកម្ពុជាយើង"។

*ដោយ អរិយបុត្រ*

### នៅកម្ពុជាមានសាលាចាប់ពីមត្តេយ្យសិក្សាទៅដល់ឧត្តមសិក្សាជាង១០០,០០០កន្លែង

*លោកហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាបានថ្លែងថា នៅកម្ពុជាមានគ្រឹះស្ថានមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សាទាំងរដ្ឋ និងឯកជនជាង ១ម៉ឺនកន្លែង។*

*លោកបានថ្លែងថា យើងមានសាលាមត្តេយ្យសិក្សាចំនួន ៤.៤០៧, សាលាបឋមសិក្សាចំនួន ៧.៥៦១, អនុវិទ្យាល័យចំនួន ១.៣០០ និងវិទ្យាល័យចំនួន ៦០៨។*

*លោកបានបន្តទៀតថា រីឯគ្រឹះស្ថានឧត្តមសិក្សាយើងមានចំនួន ១២១ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន ៤៨ និងឯកជនចំនួន ៧៣កន្លែងនៅក្នុងរាជធានី និង ខេត្តចំនួន២០។*

*លោកបានបន្តទៀតថា គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំយុវជន និងកីឡាមានចំនួន៧៣ ក្នុងនោះរដ្ឋចំនួន ១៣ និងឯកជនចំនួន ៦០កន្លែង ដោយឡែក គ្រឹះស្ថានឧត្តមសិក្សាចំនួន ១៦ផ្សេងទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង និងស្ថាប័នដទៃ។*

# ពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា ដល់សិក្ខាកាមជំនាន់ទី១ និងជំនាន់ទី២



ថតដោយ ឡុង សម្ផស្ស

ពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា ដល់សិក្ខាកាមជំនាន់ទី១ និងជំនាន់ទី២ សិក្ខាកាមជាស្ត្រីចំនួន៥៥នាក់ ទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា ក្រោយពីបានសិក្សា នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈស្ត្រី របស់អង្គការការីតាសបាត់ដំបងអស់រយៈពេលពី៦ខែ ដល់១ឆ្នាំ។

ពិធីប្រគល់វិញ្ញាបនបត្រនេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២១ ខែមីនានេះ ក្រោមអធិបតីលោក អេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការការីតាសកម្ពុជា ឯកឧត្តមនឹម ថូ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ប្រធានអង្គការការីតាសកម្ពុជា អាណាព្យាបាលនិងសិស្សានុសិស្សជាច្រើនរូប។ លោកអភិបាល អេនរីគេ ហ្វីការេដូ បានមានប្រសាសន៍ថា នៅថ្ងៃនេះជាថ្ងៃពិសេស គឺយើងពិតជាមានអំណរសប្បាយ និងរីករាយចំពោះលទ្ធផល ដែលយើងមាននាឱកាសនេះ។ ទាំងថ្នាក់ដឹកនាំបុគ្គលិក លោកគ្រូអ្នកគ្រូ អាណាព្យាបាល ព្រមទាំងសិក្ខាកាមទាំងអស់ ដែលបានសិក្សានៅ ក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រី របស់អង្គការការីតាស គឺគ្រប់គ្នាបានសហការគ្នាបានយ៉ាងល្អ ដែលនាំឲ្យយើងសម្រេចបាននូវផលផ្លែល្អ ហើយនាំឲ្យយើងទៅខាងមុខ។ ប្រសិនបើយើងមិនចេះសហការគ្នា យើងមិនចេះធ្វើការជាមួយគ្នា នោះយើងមិនអាចទៅខាងមុខបាននោះទេ។ លោកអភិបាលបន្តថា អ្វីដែលបងប្អូនទទួលបានពីទីនេះ គឺទទួលបានចំណេះដឹងខាងមុខរបរ ចំណេះអំពីជីវិត និងបទពិសោធន៍ដែលមានតម្លៃនាំឲ្យយើងដើរទៅខាងមុខ។ ការងារអង្គការការីតាស ជួយឲ្យអ្នកដែលមានបញ្ហានៅក្នុងជីវិត ដែលក្រ គ្មានមធ្យោបាយ ចំណេះ និងមុខរបរ ជួយឲ្យពួកគេបានទទួលតម្លៃនៃជីវិត និងងើបឡើងដើរឆ្ពោះទៅខាងមុខ ដោយជំនះនូវគ្រប់ឧបសគ្គក្នុងជីវិតដែលខ្លួនមាន។ លោកអភិបាលបានផ្តាំផ្ញើដល់មាតាបិតា និងអាណាព្យាបាលទាំងអស់ សូមជួយបន្តគាំទ្រ កូនៗរបស់ខ្លួនដើម្បីអាចក្រោកឈរ និងដើរទៅមុខទៀតក្នុងការទទួលបានការងារល្អ សម្រាប់ជួយឲ្យជីវភាព ក្រុមគ្រួសារកាន់តែប្រសើរ។ ឯកឧត្តមនឹម ថូ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានមានប្រសាសន៍លើកទឹកចិត្ត ដល់សិក្ខាកាមទាំងអស់ ឲ្យខិតខំប្រឹងប្រែងរៀនសូត្រក្រេបយកចំណេះវិជ្ជាទាំងនេះ ដើម្បីអនាគតរបស់ខ្លួននិងក្រុមគ្រួសារ។លោកសម្តែងនូវការអបអរសាទរចំពោះសិក្ខាកាម ដែលបានបញ្ចប់ការសិក្សានាពេលនេះ ហើយក៏សូមអបអរសាទរនូវស្នាដៃ ដែលកើតមកពីការខិតខំ ប្រឹងប្រែងសិក្សាកន្លងមកនេះ។ ឯកឧត្តម ក៏សូមថ្លែងអំណរគុណដល់អង្គការការីតាសកម្ពុជា ដែលបានជួយដល់ប្រជាពលរដ្ឋខ្មែរ នៅក្នុងការកសាងជីវភាពថ្មី ពីការរៀនយកជំនាញពីមជ្ឈមណ្ឌលនេះ។

អ្នកស្រីគុណ គឹមស្រ៊ាង ប្រធានគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីរបស់អង្គការការីតាស បានលើកឡើងថា មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនេះ ត្រូវបានសាងសង់ឡើងក្នុងគោលបំណងដើម្បី ជួយស្ត្រីក្រីក្រ មានវិបត្តិ គឺផ្តល់ពួកគាត់ឲ្យមានជំនាញវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ដោយផ្តល់ទាំងចំណេះ ជំនាញ ព្រមទាំងអប់រំអំពីសុខភាពផ្លូវចិត្ត និងបំណិនជីវិត។អ្នកស្រីប្រធានគ្រប់គ្រងមជ្ឈមណ្ឌលបានបន្តថា មណ្ឌលធ្វើការជាមួយស្ត្រី ដែលរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ស្ត្រីជួបវិបត្តិ ស្ត្រីរងគ្រោះនានា និងស្ត្រីដែលជាម្តាយវ័យក្មេង ដែលឱកាសដើម្បីសិក្សាជំនាញផ្សេងៗ ខណៈពួកគេមានកូននៅពេលវ័យក្មេងនោះ។

អ្នកស្រី ថង ចន្ទី ជាតំណាងអាណាព្យាបាលចាប់អារម្មណ៍ និងថ្លែងអំណរគុណដល់អង្គការការីតាស ដែលបានបង្កើតកម្មវិធី និងសាលាដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់យុវនារី និងស្ត្រីជាម្តាយវ័យក្មេង ដែលនាំឲ្យពួកគាត់ទទួលបានចំណេះជំនាញមួយពិតប្រាកដ និងបានចូលរួមចំណែកក្នុងសង្គម។

ក្នុងនាមជាអាណាព្យាបាល អ្នកស្រីបានលើកជាសំណូមពរ និងមានមតិផ្តាំផ្ញើ ដល់អង្គការការីតាសកម្ពុជា មេត្តាបន្តជួយទៅដល់ស្ត្រីខ្មែរជាច្រើនទៀត ដែលកំពុងទទួលរងគ្រោះ ត្រូវការនូវការជួយឧបត្ថម្ភគាំទ្រពីអង្គការដៃគូនានា។ សូមឲ្យមាតាបិតា និងស្ត្រីទាំងអស់ដែលរងគ្រោះ ដែលមានឱកាសបានរៀនសូត្រនៅទីនេះ មេត្តាខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់នៅក្នុងការសិក្សា ដើម្បីរៀបចំអនាគតរបស់ខ្លួនឲ្យបានល្អប្រសើរ។

ជាសិស្សជំនាន់ទី១ រៀនលើមុខវិជ្ជាសំអាងកាយ និងកែសម្ផស្ស ដែលត្រូវទទួលវិញ្ញាបនបត្រ បញ្ជាក់ការសិក្សាកញ្ញា សារឿន លីណា បានឡើងចាប់អារម្មណ៍ថា ក្នុងឱកាសនេះ កញ្ញាសូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការការីតាស ដែលបានជួយឧបត្ថម្ភគាំទ្រ និងផ្តល់ឱកាសដល់ កញ្ញា ក៏ដូចជាស្ត្រីផ្សេងៗទៀត ឲ្យទទួលបាននូវមុខជំនាញ ក៏ដូចជាមេរៀនបំណិនជីវិតជាដើម។ កញ្ញាបន្តថា នៅមុនពេលបានចូលរៀននៅទីនេះ កញ្ញាគ្មានជំនាញអ្វីមួយច្បាស់លាស់នៅឡើយ សម្រាប់ប្រកបរបរចិញ្ចឹមជីវិតនោះ ប៉ុន្តែក្រោយពីបានរៀននៅទីនេះ និងបន្ទាប់ពីបញ្ចប់ការសិក្សា នៅទីនេះកញ្ញាអាចស្វែងរកការងារធ្វើបាន។ គួរបញ្ជាក់ថា សិក្ខាកាមដែលបានបញ្ចប់ការសិក្សានៅលើមុខជំនាញទាំងនោះមានដូចជា ជំនាញកាត់ដេរ សំអាងកាយ និងកែសម្ផស្ស សិប្បកម្មកែច្នៃ ផ្នែកធ្វើម្ហូប និងភោជនីយដ្ឋាន និងផ្នែកតម្បាញ ដែលបានទទួលនូវការឧបត្ថម្ភគាំទ្រពីអង្គការការីតាសទាំងស្រុងក្នុងអំឡុងពេលសិក្សា និងស្នាក់នៅរហូតដល់បញ្ចប់វគ្គនីមួយៗ។

*ដោយ ឡុង សម្ផស្ស*

# មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីរបស់អង្គការការីតាសបាត់ដំបងត្រូវបានដាក់សម្ពោធជាផ្លូវការ

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ស្ត្រី និងស្ត្រីជាម្តាយវ័យក្មេង របស់អង្គការការីតាស់កម្ពុជា ដែលស្ថិតនៅភូមិសំរោង ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង បានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ នៅព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងជាប្រធានក្រុមប្រឹក្សាភិបាលអង្គការការីតាសកម្ពុជា លោកគឹម រតនា នាយកប្រតិបត្តិអង្គការរីតាសកម្ពុជា ដោយមានការចូលរួមពីសំណាក់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន ព្រមទាំងបងប្អូនប្រជាពលរដ្ឋ និងសិស្សានុសិស្សយ៉ាងច្រើនកុះករ។

លោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ជាប្រធានក្រុមប្រឹក្សាភិបាលអង្គការការីតាសកម្ពុជា បានមានប្រសាសន៍ថា ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ស្ត្រី និងស្ត្រីជាម្តាយវ័យក្មេង គឺសម្រាប់អ្នកក្រីក្រ អ្នកទន់ទាប និងអស់អ្នកដែលសង្គមមិនសូវផ្តល់តម្លៃ។ អង្គការ ការីតាស ធ្វើសកម្មភាពទាំងអស់នេះ គឺលើកទឹកចិត្តដល់អ្នកតូចតាច លើស្ទួយជីវភាពពួកគាត់ឲ្យប្រសើរជាងមុន និងមានកិត្តិយសក្នុងសង្គម លោកអភិបាលបានបញ្ជាក់ថែមទៀតថា អង្គការការីតាសបានខិតខំធ្វើសកម្មភាពទាំងនេះ គឺមានបំណងតែមួយគត់ គឺបង្ហាញធម៌មេត្តាករុណាដល់អ្នកក្រីក្រ ដល់អ្នកតូចតាច ដល់មនុស្សដែលសង្គមមិនទទួលស្គាល់ថា ពួកគាត់មានកិត្តិយស ជាបុត្រធីតារបស់ព្រះជាម្ចាស់។

លោកអភិបាលបានសង្កត់ធ្ងន់ថា "ក្នុងគ្រប់កម្មវិធីទាំងអស់ ដែលអង្គការការីតាសមាន គឺដើម្បីបង្ហាញឲ្យអ្នកក្រីក្រ អ្នកតូចតាចទាំងនោះ ទទួលស្គាល់ថា ពួកគាត់មានកិត្តិយស ពួកគាត់មានសិទ្ធិ ដោយព្រះជាម្ចាស់បានបង្ហាញធម៌មេត្តាករុណា និងសេចក្តីស្រឡាញ់ចំពោះពួកគាត់ គឺយើងប្រៀបបីដូចជាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលសម្រេចបាននូវកិច្ចការទាំងអស់នេះ"។

ថ្លែងក្នុងឱកាសនោះ សម្តេចក្រឡាហោមស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែង អំណរគុណ និងកោតសរសើរដល់ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំទាំងអស់ នៃអង្គការការីតាសកម្ពុជា ដែលបានយកចិត្តទុកដាក់ជួយប្រជាពលរដ្ឋកម្ពុជា តាមរយៈកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ដើម្បីជួយ គាំទ្រក្នុងការអភិវឌ្ឍន៍ទៅដល់សហគមន៍មូលដ្ឋាន រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ សម្តេចបន្តថា នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំជំរុញលើការអភិវឌ្ឍន៍ទៅលើវិស័យចំនួន៤គឺ ការកសាងធនធានមនុស្ស ការកសាងផ្លូវ ជួយដោះស្រាយបញ្ហាទឹក និងបញ្ហាភ្លើងជាដើម។ សម្តេចក្រឡាហោម មានប្រសាសន៍បន្ថែមថា បើយើងក្រឡេកមកមើលនៅទីនេះវិញ ជាពិសេស នៅក្នុងខេត្តបាត់ដំបងនេះ ជាក់ស្តែងអង្គការការីតាសកម្ពុជា ក៏បានចូលរួម ហើយក៏និងកំពុងជួយ ទៅលើផ្នែកជាច្រើនដូចជា ការរួមចំណែកការកសាងធនធានមនុស្ស ដែលជាវិស័យដ៏ចាំបាច់ និងមានសារប្រយោជន៍ នៅក្នុងកិច្ចការកសាងប្រទេសកម្ពុជាទៅថ្ងៃអនាគត ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រី របស់អង្គការការីតាសកម្ពុជាបានចាប់ផ្តើមកសាង តាំងពីឆ្នាំ២០១៤។ អភិបាលខេត្តបាត់ដំបង ឯកឧត្តមចន្ទ សុផល បានមានប្រសាសន៍ថា មណ្ឌលនេះពិតជាបានផ្តល់នូវក្តីសង្ឃឹមសម្រាប់ស្ត្រី និងអ្នកម្តាយ វ័យក្មេង ដែលបានរងគ្រោះ និងទទួលផលប៉ះពាល់ពីបញ្ហាចំណាកស្រុក ដោយទុកឱកាសឲ្យពួកគាត់បានការកសាងជីវិតថ្មី។ ឯកឧត្តមចន្ទ សុផល បានមានប្រសាសន៍បន្តថា ក្នុងនាមថ្នាក់ដឹកនាំខេត្តបាត់ដំបងទាំងមូល ឯកឧត្តម សូមថ្លែងអំណរគុណដល់អង្គការការីតាសកម្ពុជា អង្គការការីតាសស្វីស និងអង្គការដៃគូសហការ ផ្សេងៗទៀត ដែលបានជួយជ្រោមជ្រែងធ្វើឲ្យគម្រោងទាំងអស់នេះ បានកើតចេញជារូបរាង និងទទួលលទ្ធផលជាផ្លែផ្កាឡើង។ ជាមួយគ្នានេះឯកឧត្តម អភិបាលខេត្តបានសន្យាជួយគាំទ្រ និងសហការសម្របសម្រួល ទៅលើគម្រោងនានារបស់អង្គការការីតាសកម្ពុជា ជាបន្តទៀតនាពេលខាងមុខ ។

នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា លោកគឹម រតនា បានលើកឡើងថា កត្តាចម្បងគឺការីតាសផ្តល់នូវសេវាកម្ម ជាពិសេសសម្រាប់ស្ត្រី ដែលងាយរងគ្រោះ ស្ត្រីដែលមានកូននៅក្មេងវ័យ ស្ត្រីដែលរងគ្រោះដោយការជួញដូរមនុស្ស និងការរំលោភបំពានក្រោមទម្រង់ផ្សេងៗ។ ការីតាសជួយឲ្យពួកគាត់បានទទួលនូវជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ដើម្បីឲ្យពួកគាត់អាចចូលទៅក្នុងសង្គមបាន។ លោកគឹម រតនា បន្តថា ជាក់ស្តែងក្នុងរយៈពេលកន្លងមក មជ្ឈមណ្ឌលបានបណ្តុះបណ្តាលដល់ក្រុមស្ត្រីបានចំនួន៥៥នាក់ ដែលបញ្ចប់ការសិក្សាលើមុខជំនាញជាច្រើនដូចជា ជំនាញកាត់ដេរ សំអាងកាយ និងកែសម្ផស្ស សិប្បកម្មកែច្នៃដោយដៃ ផ្នែកធ្វើម្ហូប និងភោជនីយដ្ឋាន និងផ្នែកតម្បាញ ដែលសិក្សាមានរយៈពេលពី៦ខែ ដល់១ឆ្នាំ ដោយទទួលបាននូវការជួយឧបត្ថម្ភគាំទ្រ ពីអង្គការការីតាសទាំងស្រុងក្នុងអំឡុងពេលសិក្សា និងស្នាក់នៅ។

កញ្ញាប៊ុន ស្រីរ័ត្ន អាយុ២១ឆ្នាំ មានស្រុកកំណើតនៅខេត្តបាត់ដំបង បានបញ្ចប់វគ្គបណ្តុះបណ្តាលផ្នែកសំអាងកា និងកែសម្ផស្សរយៈពេលមួយឆ្នាំ បានប្តេជ្ញាថា ក្រោយពីបញ្ចប់ការសិក្សានេះ រូបនាងនឹងយកជំនាញសំអាងកា និងកែសម្ផស្សទៅប្រកបរបចិញ្ចឹមជីវិតទៅថ្ងៃអនាគត។

សូមបញ្ជាក់ថា អង្គការការីតាសកម្ពុជា គឺជាអង្គការមិនមែនរដ្ឋាភិបាលជាអង្គនៃព្រះសហគមន៍កាតូលិក បានចាប់ផ្តើមសកម្មភាពជាលើកដំបូង នៅក្នុងប្រទេសកម្ពុជានាឆ្នាំ១៩៧២ ដើម្បីជួយជនរងគ្រោះដោយសារសង្គ្រាម និងបានបំពេញមុខងារមនុស្សធម៌ រហូតដល់ឆ្នាំ១៩៧៥ ដែលនៅពេលនោះ អង្គការការីតាសកម្ពុជាត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសកម្ពុជា។ អង្គការការីតាសកម្ពុជា បានបង្កើតឡើងជាថ្មីនាឆ្នាំ១៩៩០ ក្រោមអនុស្សារណៈយោគយល់ជាមួយ ក្រសួងការបរទេស តំណាងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តន៍លើគម្រោងសកម្មភាពមនុស្សធម៌ ការអភិវឌ្ឍន៍សហគមន៍ សុខាភិបាល និងបម្រើប្រជាជនក្រីក្រ។ សព្វថ្ងៃនេះកំពុងអនុវត្តគម្រោងការងារ នៅក្នុងខេត្តក្រុងចំនួន១២ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា៕

*ដោយ៖ ឡុង សម្ផស្ស*



*ពិធីកាត់ខ្សែបូសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ស្ត្រីរបស់អង្គការការីតាសកម្ពុជា។ ថតដោយ ឡុង សម្ផស្ស*

# បុណ្យរំឭកខួប៧១ឆ្នាំលោកបូជាចារ្យ គ្រឿង ប៊ូយៀប

គ្រីស្តបរិស័ទរាប់ពាន់នាក់បានមកចូលរួមក្នុងកម្មវិធីខួប៧១ឆ្នាំ នៃមរណសាក្សី ហ្វ្រង់ស្វ័រសាវីយេ គ្រឿង ប៊ូយៀប និងបុណ្យឆ្លងរូបសំណាកព្រះនាងម៉ារី នៅព្រះសហគមន៍ផ្លូវត្រី ក្រោមអធិបតីរបស់លោកអូលីវីយេ ឝ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកបូជាចារ្យជាច្រើនអង្គទៀត កាលពីថ្ងៃទី១២ មីនា ២០១៧កន្លងទៅ។

នៅក្នុងពិធីនោះ លោកអភិបាលបានមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទថា ថ្ងៃនេះយើងអរគុណដល់លោកឪពុក ប៊ូយៀប ដែលបានប្រមូលយើងយ៉ាងច្រើនជារៀងរាល់ឆ្នាំ ដើម្បីដឹងថាកន្លែងនេះជួយយើងអធិដ្ឋាន ជួបជាមួយព្រះជាម្ចាស់ និងស្តាប់ព្រះជាម្ចាស់។

លោកអូលីវីយេ បានបន្ថែមថា ព្រះជាម្ចាស់បានជ្រើសរើសលោកប៊ូយៀប តាមរបៀបដែលលោកបានបម្រើ និងស្រឡាញ់ព្រះជាម្ចាស់។

លោកបន្តថា ខ្ញុំជឿថា ព្រះជាម្ចាស់បានជ្រើសរើសយើងទាំងអស់គ្នានៅទីនេះ ដើម្បីមានជីវិតថ្មីយ៉ាងអស្ចារ្យ ដោយក្នុងទឹកដីភូមិភាគភ្នំពេញ យើងមានមរណសាក្សីជាច្រើន ដូចជាលោកឪពុកប៊ូយៀប លោកអភិបាលឆ្មារសោឡាស់ជាដើម។ល។

លោកថា តាមពិតព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យទៅជាអ្នកដ៏វិសុទ្ធ ដើម្បីរស់នៅតាមរបៀបព្រះយេស៊ូ តាំងពីថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក។

លោកបានដាស់តឿនគ្រីស្តបរិស័ទទាំងអស់ឲ្យមានការប្រុងប្រយ័ត្ន កុំមានចិត្តលោភលន់ និងងប់ជាមួយទ្រព្យសម្បត្តិ ដោយនឹកឃើញដល់អត្ថបទព្រះគម្ពីរស្តីអំពីលោកឡាសារ និងអ្នកមាន។

លោកបន្តថា ហេតុនេះព្រះសហគមន៍ណែនាំឲ្យយើងចេះប្រើទ្រព្យសម្បត្តិរបស់យើងដើម្បីចិញ្ចឹមជីវិតគ្រប់គ្រាន់ និងចេះចែករំលែកដល់អ្នកដទៃផងដែរ។

លោកអភិបាលបញ្ជាក់ទៀតថា កំពូលនៃជីវិតជាគ្រីស្តបរិស័ទគឺ ចែករំលែកសេចក្តីស្រឡាញ់ដូចលោកប៊ូយៀប និងលោកសាឡាស់ ដែលបានស្រឡាញ់រហូតបូជាជីវិតដែរ។ យុវនារី បូផល គ្រីស្តបរិស័ទព្រះសហគមន៍ផ្លូវត្រី បានថ្លែងថា ពិធីបុណ្យរំឭកដល់លោកបូជាចារ្យ ប៊ូយៀប ប្រព្រឹត្តទៅដោយរលូន គឺពិតជាព្រះអំណោយទានដែលព្រះជាម្ចាស់បានចាក់បង្ហូរមកលើព្រះសហគមន៍ផ្លូវត្រីយើងនេះ។

យុវតីក៏បានជូនពរដល់បងប្អូនទាំងអស់ និងចងចាំមិនភ្លេចនូវទឹកចិត្តសប្បុរសរបស់បងប្អូនដែលបានចូលរួមចែករំលែកទាំងថវិកា និងពេលវេលា។



*លោកអភិបាលថ្វាយ កំញ៉ានលើរូបសំណាករបស់លោកបូជាចារ្យ គ្រឿង ប៊ូយៀប។*

*ថតដោយ សុធីរិទ្ធិ*

លោកបូជាចារ្យហ្វ្រង់ស្វ័រសាវីយ៉េ គ្រឿង ប៊ូយៀប ជាជនជាតិវៀតណាម ធ្លាប់បានសិក្សានៅទេវវិទ្យាល័យនៅកម្ពុជា។ ក្រោយពីលោកបានតែងតាំងជាបូជាចារ្យកាតូលិក បានមកបម្រើព្រះសហគមន៍ផ្លូវត្រី ក្រោយមកលោកបានត្រឡប់ទៅកម្ពុជាក្រោមវិញ ដើម្បីប្រើព្រះសហគមន៍នៅទីនោះ លោកប៊ូយៀប កើតនៅថ្ងៃទី១ មករា ១៨៩៧ ហើយនៅថ្ងៃទី១២ មីនា ១៩៤៦ លោកបានទទួលមរណភាព ដោយលោកបានប្តូរជីវិតរបស់ខ្លួនសុំស្លាប់ជំនួសគ្រីស្តបរិស័ទ និងប្រជាជននៅក្នុងសម័យសង្គ្រាម។

ដោយឡែកព្រះសហគមន៍ នៅប្រទេសកម្ពុជា ជាពិសេសព្រះសហគមន៍ផ្លូវត្រីនេះ តែងតែប្រារព្ធពិធីរំឭកដល់លោកប៊ូយៀប យ៉ាងឱឡារិកជារៀងរាល់ឆ្នាំ ព្រោះជាព្រះសហគមន៍ដែលលោកធ្លាប់បម្រើដោយក្តីស្រឡាញ់ និងធ្លាប់បង្ហាញឲ្យអ្នកនៅតំបន់នោះបានឃើញ ក្រោយពេលលោកទទួលមរណភាពផងដែរ។ ពេលនេះព្រះសហគមន៍កំពុងរៀបចំឯកសារនានា ដើម្បីទទួលស្គាល់លោកជាមរណបុគ្គល។

*ដោយដាលីស*

# ពិធីបាចទឹកព្រះពរលើផ្ទះស្នាក់នៅ ទី៥ នៃមណ្ឌលអារ៉ូបពេ

អតីតការិយាល័យអង្គការការីតាសបាត់ដំបង ស្ថិតនៅប្របមាត់ស្ទឹងសង្កែ ក្នុងសង្កាត់ស្វាយប៉ោ ខេត្តបាត់ដំបង ត្រូវបានរៀបចំធ្វើជាផ្ទះស្នាក់នៅទី៥សម្រាប់យុវជន និងកុមារពិការនៃមណ្ឌលអារ៉ូបពេ នៃព្រះសហគមន៍បាត់ដំបង។ ផ្ទះនេះ និងទទួលកុមារ និងយុវជនឲ្យស្នាក់នៅក្រោយពីធ្វើពិធីប្រោសទឹកព្រះពរកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧នេះតទៅ ។



ពិធីបាចទឹកព្រះពរ បានប្រព្រឹត្តិធ្វើឡើងក្រោមអធិបតីភាពរបស់លោក អេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងមានការចូលរួមពីសំណាក់ អ្នកស្ម័គ្រចិត្ត យុវជន និងកុមារ។

មានប្រសាសន៍ទៅកាន់អ្នកចូលរួម និងអស់អ្នកស្នាក់នៅក្នុងផ្ទះនេះ លោកអភិបាល អេនរីគេ ហ្វីការេដូ បានលើកយកនិមិត្តរូប៤យ៉ាង មកបង្ហាញដូចជា ទី១រូបឈើឆ្កាងព្រះយេស៊ូ ដែលពិការជើងម្ខាង ក្នុងន័យថា ព្រះយេស៊ូលក្ខណៈរបស់មិនពេញលេញ ដោយយើងដែលជាអ្នកស្នាក់នៅក្នុងផ្ទះនេះ ឲ្យបំពេញបន្ថែមលក្ខណៈឲ្យព្រះយេស៊ូ ហើយយើងត្រឡប់ជាមនុស្សលែងពិការទៀតហើយ។ ប៉ុន្តែយើងទាំងអស់ ត្រូវតែមានសេចក្តីសង្ឃឹម និងតស៊ូទៅមុខជានិច្ច។ ទី២ គឺទៀន ដែលបង្ហាញអំពីលក្ខណៈរបស់អ្នកដែលស្នាក់នៅក្នុងផ្ទះនេះ ដោយត្រូវធ្វើជាពន្លឺសម្រាប់បំភ្លឺអ្នកដទៃដែរ។ ទី៣ សត្វកវែង ក្នុងន័យថា សូមឲ្យអ្នកស្នាក់នៅក្នុងផ្ទះនេះ ត្រូវមានបេះដូងធំទូលំទូលាយ និងត្រូវមានទស្សនវិស័យវែងឆ្ងាយ។ ទី៤ ប្រតិទិន គឺនាំឲ្យយើងជាអ្នកស្នាក់នៅក្នុងផ្ទះនេះ ចេះកត់ត្រានូវរាល់សកម្មភាព ដែលយើងបានបំពេញជារៀងរាល់ថ្ងៃនូវកិច្ចការនានា ឲ្យយើងចេះចែករំលែកដល់គ្នាទៅវិញទៅមកនូវអំណរសប្បាយរីករាយជាដើម។

តាមគម្រោងផែនការផ្ទះនេះ នឹងរៀបចំទៅជាមណ្ឌលសហគ្រិនមួយរបស់ព្រះសហគមន៍ ភូមិភាគបាត់ដំបង ដើម្បីផ្តល់ការងារដល់យុវជនយុវនារីដែលជាជនពិការ នៃមណ្ឌលអារ៉ូបពេ ដែលបានបញ្ចប់ការសិក្សាលើមុខជំនាញផ្សេងៗ។

សូមបញ្ជាក់ថា មណ្ឌលទទួលជនពិការអារ៉ូបពេ បានបង្កើតឡើងកាលពីដើមឆ្នាំ ២០០០ ដោយលោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង៕

*ដោយ ឡុង សម្ផស្ស*

# លោកយ៉ូសែបសំគីមសាន( ១៩៤២-១៩៧៥ )

## Mr. Joseph SOM KIMSAN

## គ្រហស្ថនិងជំនួយព្រះសហគមន៍



កើតនៅឆ្នាំ១៩៤២ ជាកូនរបស់តាអឿ យាយរស់ អ្នកស្រុកកំពង់គ ខេត្តកំពង់ធំ។ មានបងប្អូនម្តាយតែមួយ ៤នាក់។ លោកតារ៉ុំណៃ យកមកចិញ្ចឹមនៅជាមួយគាត់ នៅទីរួមខេត្តកំពង់ធំ នៅផ្ទះអ្នកបួស គឺនៅជាមួយអ្នកដំបាយឲ្យលោក។ ពេលធំហើយ ប្រហែល អាយុ ១២ឆ្នាំ ប្រហែលឆ្នាំ១៩៥៤ ក៏ជូនទៅរៀននៅអនុទេវវិទ្យាល័យផ្សារតូចភ្នំពេញ។

ពេលវ៉ាកង់រាល់ឆ្នាំ។ លោកតែងតែត្រឡប់មកជួយព្រះសហគមន៍។ ការងារដូចជា លោកមក ស្រុកនៅកំពង់គ ទោះបីប៉ុន្មានខែក៏លោកជួយអប់រំជំនឿ រៀបចំព្រះវិហារជាពិសេសបុណ្យធំៗ មានហាត់ចម្រៀង រាល់ការងារនៅក្នុងព្រះវិហារទាំងអស់ ដូចជាពេលមានអភិបូជា និងពិធីអគ្គសញ្ញាផ្សេងៗ។ ជួនកាលលោកជួយអប់រំមនុស្សពេញវ័យពេលរៀបចំអាពាហ៍-ពិពាហ៍ដែរ។

ឆ្នាំ១៩៧០ សេមិណៃត្រូវបិទ កូនសិស្សភាគច្រើនជាជនជាតិវៀតណាម ត្រូវចេញតាមបញ្ជារបស់រដ្ឋាភិបាល។ លោកសាន ទោះបីមិនមែនជនជាតិវៀតណាមក៏ត្រូវចេញដែរ។ ពេលនោះលោកកំពុងរៀនថ្នាក់វិទ្យាល័យ។

លោកធ្វើជាទាហានមួយរយៈ ប្រហែល ១៩៧២ ត្រូវចាត់ទៅប្រទេសថៃ ដើម្បីរៀនអំពីមុខវិជ្ជា ទាហាន។ លោកមិនមែនជាទាហានជួរមុខទេ។ លោកមកវិញឆ្នាំ ១៩៧៤ ចាប់ផ្តើមធ្វើការជាទាហានស័ក្ត២។ លោកមានសិទ្ធិយកគ្រួសារភៀសខ្លួនទៅថៃដែរ ប៉ុន្តែប្រពន្ធខ្លាចគេបាញ់យន្តហោះ ពេលនោះលោកសម្រេចចិត្ត មិនបោះបង់ចោលគ្រួសារទេ។លោកក៏អត់ទៅដែរ។

លោកមានជំនឿរឹងមាំ នឹងសង្ឃឹមលើព្រះអង្គ។ លោកដឹងថា ភ្នំពេញជិតបែក គាត់និយាយថា "ខ្ញុំសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ"។ ពេលនោះ ទោះបីមានឱកាសរត់ទៅក៏ដោយ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកត្រូវជន្លៀស ក៏ដូចជាអ្នកក្រុងភ្នំពេញ ទៅធ្វើការ ក្នុងវាលស្រែ។ នៅពេលកំពុងដើរចេញពីទីក្រុងប្រហែលនៅព្រៃកក្តាម មានទាហានមកសួរ សុំឲ្យទៅ "ទទួលសម្តេចសីហនុ"។ ពួកទាហានខ្មែរក្រហមដកតំណែងពីលោកនិងឲ្យនៅតាមទន្លេមេគង្គ។ គាត់ក៏ទៅតាមគេចូលការិយាល័យជិតមាត់ទន្លេ។ ក្រោយមកក៏ដឹងច្បាស់ថា គេយកមកសម្លាប់នៅព្រៃកក្តាមនោះតែម្តង។

---



សន្តី ម៉ារីយ៉ា គូរ៉េទី

នាងម៉ារីយ៉ា ជានារីដ៏ស្រស់ស្អាតម្នាក់ជនជាតិអ៊ីតាលី ដែលមានអាយុ ១២ឆ្នាំ។ នាងមក ពីក្រុមគ្រួសារកសិករ។ ថ្ងៃមួយអាលេសាំង ជ្រូ ជាបុរសម្នាក់ដែលមានអាយុ១៩ឆ្នាំ មានបំណងចង់រំលោភនាង។ នាងស្រែកឡើងថា ទេ! អត់ទេ! កុំប្រព្រឹត្តអំពើ អសីលធម៌! កុំប្រព្រឹត្តអំពើបាប!។ នៅពេលដែលនាងចាប់ផ្តើមប្រយុទ្ធប្រឆាំងនឹងគាត់ បុរសនោះយកកាំបិតមួយចាក់នាង១៤ដង! ម៉ារីយ៉ាដួលលើដី ហើយស្រែកយំជាខ្លាំងថា ឱព្រះជាម្ចាស់អើយ! នាងខ្ញុំកំពុងស្លាប់! ម៉ែអើយ!ៗ។ ពេលនោះ អាលេសាំង ជ្រូ រត់គេចខ្លួនចេញពីបន្ទប់បាត់ទៅ។ គេជូននាងម៉ារីយ៉ាទៅមន្ទីរពេទ្យ។ នៅទីនោះ នាងរងទុក្ខលំបាកអស់រយៈពេលពីរថ្ងៃ។ នៅពេលដែលលោកបូជាចារ្យសួរនាងថា តើនាងចង់លើកលែងទោសឲ្យឃាតកររបស់នាងឬទេ? នាងឆ្លើយតបថា ចាំ នាងខ្ញុំចង់លើកលែងទោសឲ្យគាត់មែន ព្រោះតែសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ហើយនាងខ្ញុំចង់ឲ្យគាត់បានចូលទៅស្ថានបរមសុខជាមួយនាងខ្ញុំដែរ! សូមព្រះជាម្ចាស់ប្រទានពរដល់គាត់។ ម៉ារីយ៉ាទទួលមរណភាពទាំងថើបឈើឆ្កាង និងកាន់រូបមួយពីព្រះនាងម៉ារី។ ហេតុការណ៍នេះកើតឡើងនៅឆ្នាំ១៩០២។ នៅឆ្នាំ១៩៥០ សម្តេចប៉ាបទទួលស្គាល់ថា នាងម៉ារីយ៉ាជាសន្តីបុគ្គលម្នាក់ ធ្វើជាគំរូសម្រាប់យុវជនយុវនារី ឲ្យគេរក្សាភាពបរិសុទ្ធរបស់ខ្លួនទុក។




# យុវជនជួយសាងសង់បង្គន់អនាម័យ ដើម្បីបរិស្ថានស្អាត និងសុខភាពល្អ



យុវជននៃព្រះសហគមន៍អំពៅព្រៃរួមសហការជាមួយថ្នាក់ដឹកនាំនៃមណ្ឌលសកម្មភាពតាខ្មៅ បានសាងសង់បង្គន់ចំនួន៤៥ សម្រាប់គ្រួសារជនក្រីក្រនៅភូមិបឹង៩៤ ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលចាប់ផ្ដើមពីពាក់កណ្ដាល ខែកុម្ភៈ ឆ្នាំ២០១៧ រហូតមកដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ នឹងគ្រោងបញ្ចប់នៅមុនបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ដើម្បីថែរក្សាបរិស្ថាន និងសុខភាពអ្នកភូមិ។

លោកពន្លក ពន្លឺ អាយុ ៤៧ឆ្នាំ ជាអ្នកភូមិបាននិយាយថា ប្រជាជនក្នុងភូមិបឹង ៩៤ ប្រមាណជា៩៩ភាគរយ ដែលគ្មានបង្គន់ប្រើប្រាស់ ភាគច្រើនគ្មានលទ្ធភាព និងមួយចំនួនទៀតពុំបានដឹងច្បាស់ពីផលប៉ះពាល់។ ហើយលោកបន្តថា ការធ្វើបង្គន់គឺ មួយគ្រួសារត្រូវបង់វិភាគទាន ៤០០០០រៀល ដែលមានការយល់ព្រមពីគ្រួសារទាំង ៤៥គ្រួសារ ហើយផ្នែកនៅសល់ខាងម្ចាស់ជំនួយជាអ្នកផ្គត់ផ្គង់ ហើយក្នុងនោះក៏មានការជួយយ៉ាងសរស្រោកសរស្រាំ ពីយុវជនសាមគ្គីរបស់ព្រះសហគមន៍អំពៅព្រៃ ទោះបីអាកាសធាតុក្ដៅយ៉ាងណាក៏ដោយក៏ពួកគេ ព្យាយាមអស់ពីកម្លាំងកាយ កម្លាំងចិត្ត ហើយពួកគេមានអារម្មណ៍សប្បាយរីករាយ និងធ្វើដោយក្ដីស្រលាញ់។ លោកសូមថ្លែងអំណរអរគុណយ៉ាងខ្លាំងដល់អស់ម្ចាស់ជំនួយ លោកឪពុក ហ្គេហ្វ្រី ម៉ារីយូ និងអ្នកគ្រូម៉ែន ថារី ដែលជួយសហការយ៉ាងសកម្ម ដែលធ្វើឲ្យបង្គន់ចាប់ផ្ដើមមាននៅក្នុងភូមិ ដ៏ក្រីក្រមួយនេះ ដែលជាផ្នែកមួយយ៉ាងធំ ក្នុងការការពារបរិស្ថានក្នុងប្រទេស និងពិភពលោកទាំងមូល។ លោកថា ក្នុងនាមយើងជាអ្នកភូមិបឹង៩៤ ក៏សូមសន្យាថា និងជួយថែរក្សាបង្គន់ឲ្យបានល្អ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។

យុវនារី ផូ ស្រីល័ក្ខ ជាសមាជិកក្រុមសាមគ្គី របស់ព្រះសហគមន៍អំពៅព្រៃមានអារម្មណ៍សប្បាយយ៉ាងខ្លាំង ដែលបានចុះជួយអ្នកភូមិបឹង៩៤ ដោយសារអ្នកភូមិ មានទំនាក់ទំនងយ៉ាងល្អ ជាមួយក្រុមពួកគាត់ ប៉ុន្តែអ្វីដែលខ្វះខាតនោះ គឺអនាម័យនៅក្នុងភូមិនោះផ្ទាល់តែម្ដង។ ស្រីល័ក្ខបន្តថា ខ្ញុំក៏មានគំនិតចង់ជួយ អស់ពីលទ្ធភាពរបស់ផងដែរ ចង់បង្កើតក្រុមកាយរិទ្ធ នៅក្នុងភូមិមួយនេះទៀតផង ដោយសារមានក្មេងៗច្រើន ដែលត្រូវការអប់រំបន្ថែមផ្នែកអនាម័យ និងចំណេះដឹងផ្សេងៗ។

យុវនារី ទូន រ័ត្នមុនី ជាអ្នកភូមិ បឹង៩៤ សព្វថ្ងៃរស់នៅក្នុងមណ្ឌល ហើយក៏ជាសមាជិកក្រុមសាមគ្គីរបស់ព្រះសហគមន៍អំពៅព្រៃ បានឲ្យដឹងថា ការរស់នៅភូមិបឹង៩៤ មានការពិបាកខ្លាំង ទាំងប្រាំង ទាំងវស្សា ហើយក្នុងរដូវវស្សា តែងមានទឹកជំនន់ ដែលធ្វើឲ្យលិចទំនប់ សិស្សមានការពិបាកក្នុងការទៅរៀន ដោយសារសាលានៅឆ្ងាយ ហើយក្នុងភូមិគ្មានមណ្ឌលសុភាព សាលារៀន។ កញ្ញាបន្តថា ប្រជាជននៅទីនោះតែងប្រើទូកជាមធ្យោបាយធ្វើដំណើរនៅពេលខែវស្សា រីឯរដូវប្រាំង ពុំសូវមានទឹកប្រើប្រាស់។ ប្រជាជនភាគច្រើនជាគ្រួសារក្រីក្រ ដែលជាហេតុធ្វើពួកគាត់ពុំសូវយល់ច្បាស់ពីការពារបរិស្ថាន និងការប៉ះពាល់នៃបរិស្ថាន គឺការបន្ទោបង់ពាសវាលពាសកាល នៅតាមព្រៃ និងក្នុងទឹកបឹងផ្ទាល់ ដែលជាហេតុធ្វើឲ្យប្រជាជននៅទីនោះឈឺច្រើន។ យុវតីថា មានចិត្តសប្បាយរីករាយយ៉ាងក្រៃលែងដោយសារ លោកឪពុក ហ្គេហ្វ្រី ម៉ារីយូ និងអ្នកគ្រូ ម៉ែន ថារី បានជួយស្វះស្វែងរកជំនួយ ដូចជាសព្វថ្ងៃបានជួយជាអណ្ដូងទឹកចំនួន៤ ដែលធ្វើឲ្យមានទឹកគ្រប់ប្រាំងគ្រប់វស្សា ជាពិសេសការធ្វើបង្គន់៤៥បង្គន់ ដែលធ្វើឲ្យភូមិមានបរិស្ថានល្អ និងមានអនាម័យ។

យុវជនសាមគ្គីនៃព្រះសហគមន៍អំពៅព្រៃ តែងតែមានសកម្មភាពសួរសុខទុក្ខគ្រួសារដែលខ្វះខាតនៅតាមភូនិនានាជារៀងរាល់ខែ។ ក្រៅពីអ្នកភូមិខាងលើយុវជនបានសង្កេតឃើញថា មានគ្រួសារជាច្រើនទៀតដែលត្រូវការបង្គន់ អណ្ដូងទឹក ភ្លើង សាលារៀន មណ្ឌលសុខភាព និងការចុះបង្រៀនបន្ថែម ពីអនាម័យ និងការការពារបរិស្ថាន។

*ដោយ អ៊ុក សំនៀង*

# អភិបាលព្រះសហគមន៍កាតូលិកចូលរួមគោរពវិញ្ញាណក្ខន្ធ

លោកអូលីវីយេ ផ្មីអីស្ល៊ែរ អភិបាលនៃព្រះសហគមន៍កាតូលិក កាលពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៧កន្លងទៅ បានដឹកនាំលោកបូជាចារ្យ ក្រុមគ្រីស្ដបរិស័ទប្រធានការិយាល័យនៃព្រះសហគម៍កាតូលិកភូមិភាគភ្នំពេញ ចូលរួមគោរពវិញ្ញាណក្ខន្ធសម្ដេចវិបុលបញ្ញា សុខ អាន នៅគេហដ្ឋាននៃសព ស្ថិតនៅសង្កាត់បឹងរាំង ខណ្ឌ៧មករា រាជធានីភ្នំពេញ។



ថតដោយ សុធីរិទ្ធិ

ក្រោយពីបានដាក់កាពេនផ្កា និងគោរពវិញ្ញាណសពរួច លោកអភិបាល និងប្រតិ[illegible]ថតដោយ សុធីរិទ្ធិ[illegible]ងការគួរសមជាមួយក្រុមគ្រួសារនៃសពសម្ដេចវិបុលបញ្ញាសុខ អាន ក្នុងនោះលោកអភិបាល បានសម្ដែងនូវការចូលរួមរំលែកទុក្ខ និងការសោកស្ដាយចំពោះការបាត់បង់ ស្វាមី និងឪពុកដ៏ជាទីស្រឡាញ់របស់ខ្លួន ។

នៅក្នុងសៀវភៅមរណទុក្ខ លោកអភិបាលអូលីវីយេ បានសរសេរថា យើងខ្ញុំទាំងអស់គ្នា ជាតំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា នៅថ្ងៃនេះ សូមចូលរួមសម្ដែងនូវការរំលែកទុក្ខ ជាអនេក រួមជាមួយលោកជំទាវអានីសុខ អាន និងក្រុមគ្រួសារទាំងអស់។

សូមព្រះជាម្ចាស់ ទទួលវិញ្ញាណក្ខន្ធសម្ដេចវិបុលបញ្ញាសុខ អាន នៅក្នុងព្រះរាជ្យព្រះជាម្ចាស់ នៅស្ថានបរមសុខផង។

លោកជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការ គណៈរដ្ឋមន្ត្រីដែលបានខិតខំក្នុងពលិកម្មបំរើជាតិជាង ៣០ឆ្នាំ។ ដោយសារមានស្នាដៃ ក្នុងបុព្វហេតុបំរើជាតិមាតុភូមិ នៅថ្ងៃទី១៣ ខែមីនា កន្លងទៅ លោកសុខ អាន ត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គឺព្រះបាទសម្ដេចព្រះបរមនាថនរោត្ដម សីហមុនី ត្រាស់បង្គាប់តែងតាំងគោរមងារជាសម្ដេចវិបុលបញ្ញា។

សម្ដេចវិបុលបញ្ញាសុខ អាន បានទទួលមរណភាពនៅវេលាម៉ោង១៨ និង៣០នាទីរសៀល នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ នៅមន្ទីរពេទ្យ នៃសាធារណរដ្ឋប្រជាមានិតចិនដោយរោគាពាធ។ សពសម្ដេច វិបុលបញ្ញាសុខ អាន បានរៀបចំពិធីបុណ្យគារវកិច្ចសព និងធ្វើការដង្ហែទៅបូជាតាមប្រពៃណី កាលពីព្រឹកថ្ងៃអាទិត្យ ទី១៩ ខែមីនា ឆ្នាំ២០១៧ នៅមុខវត្ត បទុមវត្តីនារាជធានីភ្នំពេញ៕

*ដោយ ដាលីស*

# ពិធីប្រសិទ្ធពរលើប្រេង ក៏ជាពេលវេលា លោកបូជាចារ្យរំឭកពាក្យសច្ចាឡើងវិញ



ថតដោយ លី សុវណ្ណា

គ្រីស្តបរិស័ទចំនួនប្រមាណជាជាង ៥០០នាក់ រួមទាំងលោកបូជាចារ្យ ជិត ១០០នាក់ បានមកជួបជុំគ្នានៅព្រះវិហារ សន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី ក្នុងពិធីអភិបូជាប្រសិទ្ធពរលើប្រេង។ ពិធីបានប្រព្រឹត្តទៅក្រោមអធិតីរបស់លោកអភិបាលទាំងបីភូមិភាគ កាលពីថ្ងៃទី៥ ខែមេសា កន្លងទៅ។

ពិតជាថ្ងៃដ៏ឱឡារិកដែលព្រះសហគមន៍ប្រារព្ធពិធីប្រសិទ្ធពរលើប្រេងបីប្រភេទ គឺប្រេងសម្រាប់លាបលើអ្នកជំងឺ ប្រេងសម្រាប់លាបលើអ្នកស្វែងយល់ និងប្រេងគ្រីស្មា សម្រាប់លាបអ្នកទទួលអគ្គសញ្ញាលាបថ្វាស តែងតាំងជាបូជាចារ្យ និងតែងតាំងលោកអភិបាល។ ក្នុងពេលនោះ ក៏ជាវេលាមួយពិសេសសម្រាប់លោកបូជាចារ្យដែលបម្រើព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជាទាំងអស់មកជួបជុំគ្នាមួយឆ្នាំម្តង នៅមុខលោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ បាត់ដំបង ភ្នំពេញ និងភូមិភាគកំពង់ចាម ដើម្បរំឭកពាក្យសច្ចារ្យរបស់ខ្លួនសាជាថ្មីឡើងវិញ។

បទភ្លេងចំរៀងលើកតម្កើងព្រះជាម្ចាស់បានចាប់ផ្តើម លោកបូជាចារ្យទាំងអស់បានដង្ហែរជាជួរតម្រង់មកទីសក្ការៈដោយមានព្រះឈើឆ្កាងនាំមុខ។

លោកអូលីវីយេ ជ្មឹតអីស្លែរ បានមានប្រសាសន៍ក្នុងធម្មទេសនា ទៅកាន់គ្រីស្តបរិស័ទ និងបូជាចារ្យទាំងអស់ដោយនាំនូវពាក្យសួរសុខទុក្ខពីសំណាក់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក្នុងឱកាសដែលពេលលោកអភិបាលទាំងបីបំពេញទស្សនកិច្ចផ្លូវការនៅក្រុងរ៉ូម។

លោកអភិបាលបានរៀបរាប់នូវអ្វីដែលលោកអភិបាលបានជម្រាបជូនសម្តេចប៉ាបអំពីជីវិតព្រះសហគមន៍នៅកម្ពុជា រួមជាមួយបូជាចារ្យដើម្បីការប្រកាសដំណឹងល្អនៅកម្ពុជា តាមរបៀបផ្សេងៗដើម្បីចែកអំណរសប្បាយនៃដំណឹងល្អទាំងនោះ។ មួយទៀត គឺរបៀបដែលយើងបង្កើតព្រះសហគមន៍ការរួមគ្នាជាធ្លុងក្នុងព្រះសហគមន៍ដែលយើងមានសាសនទូតមកពីជាង ៣០ ប្រទេសដែលធ្វើការរួមជាមួយគ្នា។ លោកអភិបាលក៏បានលើកចំណុចមួយទៀត គឺការសន្ទនា ដែលមានការសន្ទនារវាងសាសនានិងសាសនា ព្រះសហគមន៍និងវប្បធម៌ខ្មែរ។ ការសន្ទនារវាងមនុស្ស និងមនុស្ស។ លោកថា ព្រះរាជ្យព្រះជាម្ចាស់សម្រុះសម្រួលមនុស្ស និងព្រះជាម្ចាស់ព្រមទាំងមនុស្សលោក និងមនុស្សលោក។ ហើយចំណុចមួយទៀតដែល លោកបានលើកឡើង គឺឲ្យគ្រីស្តធ្វើដោយបើកចំហរចំពោះបងប្អូនឯទៀត ជាគំរូដល់បងប្អូនទាំងអស់ដោយបើកចំហរចិត្តទទួលបងប្អូនឯទៀតៗ។ មួយវិញទៀត គឺភាពស្ងៀមស្ងាត់ ដើម្បីចែករំលែកព្រះហឫទ័យមេត្តារបស់ព្រះជាម្ចាស់ដល់អស់បងប្អូនដែលអស់សង្ឃឹមនិងដែលមានសេចក្តីត្រូវការដែលយើងហៅថា "អគ្គសញ្ញាលើកលែងទោស" ដែលជាបេសកកម្មរបស់លោកបូជាចារ្យនិងលោកអភិបាល។

បន្ទាប់ពីធម្មទេសនាគឺមានពិធីប្រកាសពាក្យសច្ចារ្យ ដែលស្ម័គ្រចិត្តរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ និងបម្រើព្រះសហគមន៍ដោយចិត្តស្មោះត្រង់ បម្រើអគ្គសញ្ញា ពិធីបុណ្យផ្សេងៗ បំពេញកិច្ចការរបស់ព្រះជាម្ចាស់តាមព្រះគ្រីស្តជាគង្វាល លោកអភិបាលទាំងបីបានធ្វើពិធីប្រសិទ្ធិពរលើប្រេងទាំងបីប្រភេទ ហើយបន្តដោយពិធីអព្រះគុណព្រះជាម្ចាស់។ ចុងបញ្ចប់អភិបូជា ក៏មានការជូនផ្កាដល់លោកបូជាចារ្យម្នាក់មួយទង ប្រកបដោយអំណរសប្បាយ និងការដឹងគុណបំផុតពីសំណាក់គ្រីស្តបរិស័ទ។

លោកម៉ានុច កុមារ ជាបូជាចារ្យទទួលខុសត្រូវនៅព្រះវិហារ អន់ ជ្រេក នៃនិគមក្នុងភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា លោកមានអំណរសប្បាយនៅក្នុងគម្រប់១៣ឆ្នាំ នៃថ្ងៃរំឭកឡើងវិញ នូវពាក្យសច្ចារបស់លោក នៅពេលតែងតាំងជាបូជាចារ្យ។

លោកបានបន្តថា លោកកាន់តែមានកម្លាំងចិត្ត និងបម្រើព្រះសហគមន៍ដោយអំណរសប្បាយ។ ហើយអ្វីដែលជា អំណរសប្បាយជាងគេនោះគឺ "ខ្ញុំជាបេសកជនដែលមកប្រទេសខ្មែរ ដើម្បីផ្សព្វផ្សាយដំណឹងល្អដែលនេះ គឺជាបេសកកម្មរបស់ព្រះជាម្ចាស់"។

ជាព្រឹទ្ធាចារ្យនៅក្នុងព្រះសហគមន៍បាត់ដំបង អ្នកស្រីជាំ ប្រាជ្ញា បានចាប់អារម្មណ៍ថា នៅក្នុងពិធីប្រសិទ្ធិពរប្រេងដ៏ឱឡារិកក្នុងថ្ងៃនេះ យើងជាគ្រីស្តបរិស័ទសូមអរព្រះគុណព្រះជាម្ចាស់ និងសូមអរគុណដល់លោកអភិបាល លោកបូជា-ចារ្យទាំងអស់ ដែលបានសុខចិត្តថ្វាយខ្លួន ហើយបានលះបង់ជាច្រើន សម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា គឺបានធ្វើការសច្ចាជារៀងរាល់ឆ្នាំនៅចំពោះមុខព្រះសហគមន៍របស់ព្រះជាម្ចាស់។

*ដោយ លី សុវណ្ណា*



ថតដោយ សុធីរិទ្ធិ

# សម្តេចប៉ាបរៀបចំពិធីថ្វាយអភិបូជានៅទីលានសាធារណៈនៅទីក្រុង មីឡាន

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី ២៥ មីនា ២០១៧ នៅក្នុងអំឡុងពេល ទៅទស្សនៈកិច្ចព្រះសហគមន៍កាតូលិក នៅទីក្រុង មីឡាន ប្រទេសអ៊ីតាលី បាន រៀបចំនូវពិធីថ្វាយអភិបូជាមួយនៅទីលាន សាធារណៈនាទីក្រុងនេះ។

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា ទីកន្លែង ដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានរៀបចំ នោះ គឺនៅក្នុងឧស្សាន ម៉ុងហ្សា ដោយ បានសំដែងអំពីការផ្សព្វផ្សាយដំណឹង ល្អរបស់ព្រះយេស៊ូធ្វើជាសារមួយសម្រាប់ សង្គម និងសាធារណជននៅក្នុងអំឡុង ពេលនោះ។

នាឱកាសនោះសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក៏បានណែនាំ និងគោរពអញ្ជើញគ្រីស្ត បរិស័ទទាំងអស់ឲ្យក្លាយទៅជាសមាជិក នៃក្រុមប្រកាសដំណឹងល្អរបស់ប្រជាជន និងចៀសវាងការពិចារណានូវទ្រឹស្តីអំពី អនាគតរបស់អ្នកដ៏ទៃ។

នាឱកាសនោះសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក៏បានចោទជាសំនួរទៅគ្រីស្តបរិស័មួយ ចំនួនដែលសំនួរមួយ គឺត្រូវបានលើក ឡើងថា តើយើងអាចរស់នៅក្នុងសេចក្តី អំណរសប្បាយនៃព្រះជាម្ចាស់នាពេល បច្ចុប្បន្ននៅក្នុងទីក្រុងរបស់យើងឬទេ? និងមួយចំនួនទៀតគឺថា តើគ្រីស្តសាសនិក មានក្តីសង្ឃឹមនៅក្នុងស្ថានភាពបច្ចុប្បន្ន នៅទីនេះពេលនេះអត់?

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានបញ្ជាក់ថា នេះជាសំនួរដែលសម្រាប់វាស់ស្ទង់នូវ អត្តសញ្ញាណ និងតម្រូវការរបស់គ្រីស្តបរិស័ទ នៅក្នុងមាគារថ្មីនៃការមើលឃើញ ពីទីកន្លែងរបស់ពួកគេនៅក្នុងប្រវត្តិសាស្ត្រ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា មនុស្សមួយចំនួន គឺបានរិះគិតអំពីជីវិត អំពី ការងារ និងគ្រួសារ។ ពួកគេគិតអំពីអ្នក ក្រីក្រ និងជនឥន្តោប្រវេសន៍ អំពីក្មេងៗ និងអនាគតរបស់ពួកគេ ដូច្នេះទាំងនេះជា ទំនង់ ពួកគេចង់រិះគិតអំពីការកាត់បន្ថយ សមាជិក ឬក៏ចង់ចាកចេញពីជីវិតប្រចាំថ្ងៃ នៃគ្រួសារ ដោយសារតែការគិតអំពីអសន្តិ សុខ និងភាពមិនទៀងទាត់នៃសង្គម។

ត្រង់ចំណុចនេះសម្តេចប៉ាបបានជំរុញ ឲ្យគ្រីស្តបរិស័ទ សិក្សាស្វែងយល់ និងរៀន សិក្សាអំពីព្រះគម្ពី ដើម្បីនាំមកនៅភាព ស្ងប់ស្ងាត់ និងទុកចិត្តចំពោះសង្គម ដើម្បី បញ្ចៀសនូវការរិះគិតដែលអាចនឹងក្លាយ ជាគំនិតរវើរវាយ។

## សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូចំណាយពេលវេលាជាមួយនឹងពិរុទ្ធជននៅទីក្រុងមីឡាន

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា កាល ពីថ្ងៃទី២៥ មីនា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចំណាយពេលរបស់សម្តេចនៅជាមួយ នឹងអ្នកទោស និងពិរុទ្ធជននាពន្ធនាគារ មួយនៅក្នុងទីក្រុងមីឡាន ប្រទេសអ៊ីតាលី នៅក្នុងអំឡុងពេលនៃកម្មវិធីទស្សនកិច្ច ផ្ទាល់តាមព្រះសហគមន៍នាទីក្រុងនោះ។

ប្រភពដដែលបានរាយការណ៍ថា ពន្ធនាគារដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបាន អញ្ជើញចូលសាកសួរសុខទុក្ខបងប្អូនពិរុទ្ធ ជនទាំងនោះ គឺនៅពន្ធនាគារសាន់ វីទ័រ នៅ ក្នុងកម្មវិធីទស្សនកិច្ច នាទីក្រុងនេះរយៈ ពេលមួយថ្ងៃពេញ។

ដំណើរទស្សនៈកិច្ចនេះត្រូវបានស្វាគមន៍ដោយប្រធានគុក គឺលោក ហ្គារៀ ម៉ានហ្សីឡា និងអ្នកទោសផ្ទាល់។

គួររំឮកថា ពន្ធនាគារ សាន់ វីទ័រនេះ គឺមានពិរុទ្ធជនចំនួនជាង ៩០០នាក់ ទាំង ស្ត្រី និងបុរស ហើយក៏មានកុមារតូចៗមួយ ចំនួន ដែលរស់នៅជាមួយនឹងមាតារបស់គេ ដែលកំពុងតែជាប់នៅពន្ធនាគារនោះ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានជួបសំនេះ សំណាលជាមួយពួកគេហើយក៏បានសំដែង នូវភាពកក់ក្តៅនិងមេត្តាករុណាចំពោះពួក គេ ហើយពួកគេក៏បានបង្ហាញនូវអំណរ សប្បាយដែលបានជួបផ្ទាល់ជាមួយនឹង សម្តេចផ្ទាល់ផងដែរ ។

# ព្រះសហគមន៍កាតូលិកជំរុញឲ្យលើកកំពស់ការពារកុមារ

ការការពារនិងលើកកំពស់សិទ្ធិកុមារ គឺជាគោលការណ៍ និងចំណុចអទិភាពមួយ ដែលបុរីវ៉ាទីកង់បានលើកឡើងនៅក្នុងកិច្ច ប្រជុំ និងនៅក្នុងកម្មវិធីការទូតរបស់ខ្លួន តាំងពីដើមរហូតដល់ពេលបច្ចុប្បន្ននេះ។

លោកកាឌីណាល់ ភីធ័ ធូសុន ប្រធាន បុរីវ៉ាទីកង់បានលើកឡើងថា ការការពារ កុមារ គឺជានយោបាយការទូតកំពូលមួយ របស់បុរីវ៉ាទីកង់។

លោកបានថ្លែងនៅក្នុងកម្មវិធីប្រជុំមួយ ជាមួយ នឹងអ្នកការទូតមួយក្រុមកាលពី ថ្ងៃទី២៤ មីនា ២០១៧ នេះថា ខ្ញុំគឺមកពី កិច្ចការមួយ ដែលតម្រូវឲ្យនិយាយ និង លើកឡើងតែពីបញ្ហាសិទ្ធិមនុស្ស និង យុត្តិធម៌ ប៉ុន្តែនោះគឺជាកិច្ចការចម្បង និងសំខាន់របស់បុរីវ៉ាទីកង់។

តាមទីភ្នាក់ងារព័ត៌មានកាតូលិក លោក កាឌីណាល់បានថ្លែងថា នៅក្នុងនាមព្រះ សហគមន៍កាតូលិក និងនៅក្នុងឋានជា ប្រមុខនៃការិយាល័យ ដែលធ្វើការទាក់ទង នឹងសិទ្ធិមនុស្ស ការលើកកំពស់ការយល់ដឹង អំពីអ្វីដែលកំពុងបន្តកើត ខ្ញុំយល់ថា នេះគឺជា កិច្ចការដែលព្រះសហគមន៍កាតូលិកជា ពិសេស គឺបុរីវ៉ាទីកង់ និងបណ្តាប្រទេស នានា ត្រូវតែយកចិត្តទុកដាក់។

លោកថ្លែងថា កិច្ចការនេះមិនមែនជាកិច្ច ការធម្មតានោះទេ នេះគឺជាកិច្ចការដ៏សំខាន់ របស់ពិភពលោកដើម្បីបន្តការយកចិត្តទុក ដាក់ទៅលើបញ្ហាកុមារ សិទ្ធិមនុស្ស។ល។

## បុរីវ៉ាទីក្រុងផ្សព្វផ្សាយអំពីសារលិខិតសម្តេចប៉ាបហ្វ្រង់ស៊ីស្កូទៅបណ្តា ប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាលសហគមន៍អឺរ៉ុប

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា កាល ពីថ្ងៃទី២៤ មីនា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចេញនូវសារមួយដើម្បីថ្លែងទៅកាន់ បណ្តាមេដឹកនាំដែលជាប្រមុខរដ្ឋ និង ប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសនៅ សហគមន៍អឺរ៉ុប។

សារនេះត្រូវបានរៀបចំសម្រាប់កម្មវិធី មួយដែលត្រូវបានរៀបចំឡើងនៅមុនខួប ទី៦០ឆ្នាំ នៃការចុះហត្ថលេខាលើសន្ធិសញ្ញាស្តីអំពីការបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប និងសហគមន៍ថាមពលអាតូមិច អឺរ៉ុប ដែលនោះត្រូវបានគេដឹងថា គឺជាការ បើក ផ្លូវនៃការបង្កើតសហភាពអឺរ៉ុបនាពេល បច្ចុប្បន្ននេះ។

នៅក្នុងសារនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងដោយរំលឹកអំពីភាពចងចាំកាល ពីអតីតកាល និងបានលើកឡើងនូវសារៈ សំខាន់និងកិច្ចការជាច្រើនដែលសហភាព អឺរ៉ុបអាចសម្រេចបាននាពេលបច្ចុប្បន្ន នេះថែមទៀតផង ។

នាឱកាសនោះសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានថ្លែងអំពីបញ្ហាប្រឈម មួយចំនួន ប៉ុន្តែបានលើកទឹកចិត្តឲ្យបណ្តាមេដឹកនាំ នៃបណ្តាប្រទេសនៅក្នុងសភាពអឺរ៉ុបទាំង អស់បន្តការខិតខំដើម្បីប្រឈមនឹងអ្វីដែល កើតមាននៅថ្ងៃនេះ និងថ្ងៃស្អែក ហើយ ក៏បានរំលេចនូវព្រះគម្ពីមួយចំនួនផងដែរ ដោយថ្លែងថា ព្រះគម្ពី គឺអាចបង្រួចប្រវត្តិសាស្ត្រដ៏ទូលំទូលាយបាន ហើយក៏អាច បង្រៀនយើងនូវមេរៀន ដែលជាមូលដ្ឋាន នៃការគិតផងដែរ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៥៧ គឺជាការ បើកនូវទំព័រថ្មីមួយនៅក្នុងពិភពលោកជា ថ្ងៃពោរពេញដោយក្តីសង្ឃឹម ហើយជា ថ្ងៃប្រវត្តិសាស្ត្រមួយដ៏សំខាន់របស់អឺរ៉ុប ហើយក៏បានជំរុញឲ្យពលរដ្ឋនៅអឺរ៉ុបបន្ត ដើរទៅមុខ ប្រកបដោយដំណឹងល្អនិង ជំនឿទុកចិត្តខ្លួនឯង ។

# ភូមាច្រានចោលការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិអំពីឧក្រិដ្ឋកម្មប្រឆាំងជនជាតិរ៉ូហ៊ីងយ៉ា

ប្រទេសមីយ៉ាន់ម៉ាដែលគេស្គាល់ជាទូទៅថា ភូមា កាលពីថ្ងៃទី២៥ ខែមីនា បាន ច្រានចោលការសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្នុងការស៊ើបអង្កេតការចោទប្រកាន់ដែលថា ក្រុមមន្ត្រីសន្តិសុខមីយ៉ាន់ម៉ាបានសម្លាប់ រំលោភ និងធ្វើទារុណកម្ម ជនជាតិមូស្លីមរ៉ូហ៊ីងយ៉ា ដោយបាននិយាយថា ការស៊ើប អង្កេតនេះនឹងរឹតតែបញ្ឆេះភ្លើងជម្លោះខ្លាំងឡើង។

កាលពីថ្ងៃសុក្រ អង្គការសហប្រជាជាតិ បានយល់ព្រមបញ្ជូនក្រុមបេសកកម្ម ស្វែងរកការពិត ទៅប្រទេសមីយ៉ាន់ម៉ាដើម្បីស៊ើបអង្កេតលើការអះអាងដែលថា ប៉ូលិស និងទាហានមីយ៉ាន់ម៉ាបានប្រព្រឹត្តការរំលោភបំពាន លើក្រុមជនជាតិរ៉ូហ៊ីងយ៉ា នៅរដ្ឋរ៉ាក់ឃីន។

ការបង្ក្រាបដោយកងទ័ពមីយ៉ាន់ម៉ា ដែលបានចាប់ផ្តើមកាលពីខែតុលា បន្ទាប់ពី ពួកសកម្មប្រយុទ្ធបានសម្លាប់ប៉ូលិសចំនួន៩នាក់មកនោះ បានបណ្តាលឱ្យជនជាតិ រ៉ូហ៊ីងយ៉ារាប់ម៉ឺននាក់រត់ភៀសខ្លួនឆ្លងកាត់ព្រំដែន ចូលប្រទេសបង់ក្លាដែស។ ពួកអ្នក រត់គេចខ្លួនរួច បានប្រាប់ក្រុមអ្នកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិថាក្រុមមន្ត្រី សន្តិសុខភូមាបានចាក់សម្លាប់ទារក ដុតមនុស្សទាំងរស់ និងប្រព្រឹត្តអំពើចាប់រំលោភ។

ក្រសួងការបរទេសភូមា កាលពីថ្ងៃទី២៥ ខែមីនា មិនបាននិយាយថា ខ្លួននឹងរារាំង ការស៊ើបអង្កេតដែលគាំទ្រ ដោយអង្គការសហប្រជាជាតិនេះទេ ប៉ុន្តែបាននិយាយថា ខ្លួនបានដកខ្លួនចេញទាំងស្រុងពីការសម្រេចនេះ។

ក្រសួងការបរទេសភូមា បានបន្ថែមថា "ការបង្កើតបេសកកម្មស្វែងរកការពិតអន្តរ ជាតិនេះនឹងបញ្ឆេះភ្លើងជម្លោះបន្ថែមទៀត ជាជាងដោះស្រាយបញ្ហានៅពេលនេះ"។

មីយ៉ាន់ម៉ាកំពុងធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួនលើការចោទប្រកាន់អំពីឧក្រិដ្ឋកម្ម នៅរដ្ឋរ៉ាឃីន ៕

# អត្ថាធិប្បាយព្រះគម្ពីរខែមេសា ឆ្នាំ ២០១៧ ដោយ លោកវឿន ឆ័ត្រសិរី



### ថ្ងៃអាទិត្យទី ២៖ សប្តាហ៍ទី ៥ រដូវសែសិបថ្ងៃ

ឆ្នាំនេះជាឆ្នាំកហើយព្រះសហគមន៍តែងយកព្រះបន្ទូលឆ្នាំកនេះ សម្រាប់ព្រះសហគមន៍ដែលមានបេក្ខជនរៀបចំទទួលអគ្គសញ្ញាជ្រមុជទឹក។ អាទិត្យនេះទាក់ទងនឹងលោកឡាសារ ដែលព្រះយេស៊ូ ហៅគាត់មានជីវិតឡើងវិញចេញពីផ្នូរ។ ផ្នូរជាកន្លែងសម្រាប់មនុស្សស្លាប់ ហើយលោកឡាសារ គឺជាតំណាងយើងទាំងអស់គ្នា។ យើងត្រូវព្រះយេស៊ូចេញពីសេចក្តីស្លាប់ មកកាន់ជីវិតក្នុងអង្គព្រះយេស៊ូ។ យើងត្រូវព្រះអង្គត្រាស់ហៅរាល់ថ្ងៃ ឲ្យមានជីវិតរស់ឡើងវិញ ដូច្នេះហើយ ពេលយើងរស់នៅដោយជៀសវាងបាប និងអនុវត្តតាមព្រះបន្ទូល ពិតជាយើងមានជីវិតមែន។ ម្យ៉ាងទៀត ព្រះអង្គស្រឡាញ់ និងអាណិតលោកឡាសារ រហូតដល់ព្រះអង្គយំយ៉ាងណា ក៏ព្រះអង្គអាណិតនិងយំ នៅពេលឃើញយើងធ្វើអំពើបាប យ៉ាងនោះដែរ។ សូមបងប្អូនដឹងខ្លួនជានិច្ចថា ទោះបីយើងជាមនុស្សបាបក៏ព្រះអង្គនៅតែស្រឡាញ់យើង។

### ថ្ងៃអាទិត្យទី ៩ ៖ បុណ្យហែស្លឹក (ព្រះយេស៊ូរងទុក្ខលំបាក)

យើងបានស្តាប់ព្រះបន្ទូលពីលោកម៉ាថាយ យ៉ាងវែងថ្ងៃនេះ ដោយសារតែព្រះសហគមន៍ចង់ឲ្យយើងរួមធ្វើដំណើរជាមួយព្រះយេស៊ូទៅកាន់សេចក្តីស្លាប់ដែលជាសេចក្តីពិតមួយរបស់មនុស្ស។ យើងមានតួក្នុង ដំណើររឿងការរងទុក្ខរបស់ព្រះអង្គច្រើនណាស់ ដែលចូលសេចក្តីពិតរបស់យើងដែរថា យើងត្រូវជួបបញ្ហា ការក្បត់ចិត្ត ការបំពាន ធ្វើបាបពីអ្នកជុំវិញយើង។ សូមបងប្អូនមើលក្រុមសាវ័ក ដែលធ្លាប់នៅជាមួយព្រះអង្គ នៅពេលនេះទាំងអស់គ្នាបោះបង់ចោលព្រះអង្គ។ លោកសិលាក៏បដិសេធមិនទទួលស្គាល់ព្រះយេស៊ូជាច្រើនដង។ លោកពីឡាតដែលមានអំណាចខាងនយោបាយ មិនអាចធ្វើអ្វីបាន ហើយសុខចិត្តឲ្យមនុស្សបរិសុទ្ធម្នាក់ត្រូវយកទៅឆ្កាង។ ស៊ីម៉ូន អ្នកស្រុកគីរេនដែលជួយព្រះយេស៊ូពីលើឈើឆ្កាង។ ពួកយូដា ដែលស្រែកឲ្យយកព្រះយេស៊ូទៅឆ្កាង។ ទាហាន ដែលទទួលស្គាល់ថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។

យើងពិចារណាមើលថា តើយើងប្រៀបដូចជាអ្នកណាខ្លះ ដែលនៅជុំវិញព្រះយេស៊ូ? ហើយយើងបានផលផ្លែអ្វីខ្លះពីការសោយទិវង្គត់របស់ព្រះអង្គ? តើយើងចូលក្នុងការរងទុក្ខអ្វីខ្លះជាមួយព្រះអង្គ?

### ថ្ងៃអាទិត្យទី ១៦ ៖ បុណ្យឱឡារិកបុណ្យចំលង

បុណ្យចម្លង គឺជាបុណ្យកំពូលជាងគេ នៃពិធីបុណ្យនិងជាជីវិតរបស់គ្រីស្តបរិស័ទកាតូលិក។ បុណ្យនេះ នាំឲ្យយើងយល់អត្ថន័យជីវិតជាគ្រីស្តបរិស័ទ ដែលត្រូវរងទុក្ខដល់ស្លាប់ជាមុនសិន ទើបទទួលនូវជីវិតថ្មី រួមជាមួយព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ នេះយើងហៅថា "អាថ៌កំបាំងនៃបុណ្យចម្លង"។ គ្រីស្តបរិស័ទត្រូវរួមធ្វើដំណើរជាមួយព្រះយេស៊ូបែបនេះអស់មួយជីវិត គឺ"រងទុក្ខវេទនា, ស្លាប់ និងរស់ឡើងវិញ"។ យើងត្រូវពិនិត្យមើលជីវិតរបស់យើងឲ្យច្បាស់តាមជំនឿទោះបីយើងដូចសាវ័ក ២នាក់ដែលព្រះបន្ទូលនិយាយថា "ក្រុមសាវ័កពុំទាន់យល់អត្ថន័យគម្ពីរដែលចែងទុកថា ព្រះយេស៊ូត្រូវមានព្រះជន្មរស់ឡើងវិញនៅឡើយទេ" (យហ.២០,៩) មានន័យថា ពេលនេះគាត់មិនទាន់យល់ ប៉ុន្តែពេលណាគាត់យល់ សូម្បីតែជីវិតពួកគេក៏អាចលះបង់បានដែរ។ សូមពិនិត្យមើលជីវិតសន្តបុគ្គលទាំងអស់ ជាពិសេស ជីវិតមរណសាក្សីទាំងឡាយ។

### ថ្ងៃអាទិត្យទី ២៣ ៖ សប្តាហ៍ទី ២ ក្នុងរដូវបុណ្យចម្លង

សម្តេចប៉ាបយ៉ូហានប៉ូលទី២ បានប្រកាសឲ្យសប្តាហ៍នេះ ជាថ្ងៃប្រារព្ធបុណ្យព្រះហឫទ័យមេត្តារបស់ ព្រះយេស៊ូគ្រីស្ត។ យើងមើលព្រះបន្ទូលពីសន្តយ៉ូហាន ដែលរៀបរាប់ការបង្ហាញខ្លួនរបស់ព្រះយេស៊ូក្រោយបានព្រះអង្គមានព្រះជន្មថ្មីដ៏រុងរឿង។ "សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត"។ (យហ.២០,១៩) ព្រះអង្គអាណិតមេត្តាចង់ឲ្យយើងទាំងអស់ មានក្តីសុខសាន្ត ដោយមានជីវិតថ្មីរួមជាមួយព្រះអង្គ។ ព្រះអង្គចង់ឲ្យយើងទាំងអស់គ្នា ជាសាសនទូតនាំដំណឹងល្អនេះ ទៅប្រកាសឲ្យមនុស្សទូទាំងពិភពលោកស្គាល់ព្រះអង្គដូចសាវ័កដែលប្រាប់លោកថូមាសថា "យើងបានឃើញព្រះអម្ចាស់"។ (យហ.២០,២៤)

សូមឲ្យបុណ្យចម្លង គឺជាឱកាសឲ្យយើងនាំសេចក្តីសុខសាន្តពីព្រះយេស៊ូ ទៅប្រាប់អ្នកដទៃដោយដឹងថា ព្រះយេស៊ូស្រឡាញ់អាណិតមេត្តាយើងជានិច្ច។

### ថ្ងៃអាទិត្យទី ៣០ ៖ សប្តាហ៍ទី ៣ ក្នុងរដូវបុណ្យចម្លង

ព្រះបន្ទូលថ្ងៃនេះ ជួយឲ្យយើងរួមធ្វើដំណើរជាមួយព្រះយេស៊ូ ដែលធ្វើដំណើរជាមួយសិស្ស២នាក់ ទៅភូមិអេមាអូស ពួកគេកំពុងអស់សង្ឃឹម ហើយចេញពីក្រុងយេរូសាឡឹម ជាកន្លែងដែលព្រះយេស៊ូសោយទិវង្គត។ យើងក៏អាចអស់សង្ឃឹម ដូចគ្នាដែរ គឺ យើងអាចមានពេលខ្លះ គឺអស់សង្ឃឹម បណ្តោយជីវិតទៅតាមខ្សែសង្គម ដោយភ្លេចថា ជារៀងរាល់ថ្ងៃ យើងមានព្រះយេស៊ូគង់ជាមួយយើង។

សិស្សទាំងពីរចាំព្រះអង្គបាន នៅពេលធ្វើពិធីកាច់នំប៉័ង នេះគឺជាហេតុការណ៍ ដែលនាំឲ្យយើងជាគ្រីស្តបរិស័ទសព្វថ្ងៃ ត្រូវចាំ និងមើលឃើញព្រះយេស៊ូ នៅពេលចូលរួមពិធីអរព្រះគុណ(ឬហៅថាអភិបូជា) ព្រោះនៅពេលនោះ យើងបានឃើញព្រះកាយព្រះអង្គ និងបានស្តាប់ព្រះបន្ទូលដែលព្រះអង្គពន្យល់។

តួនាទីរបស់យើងគឺ រំលឹកវត្តមានរបស់ព្រះអង្គនៅក្នុងជីវិតរបស់យើង ហើយចែករំលែក បទពិសោធន៍ ដែលយើងបានឃើញឲ្យអ្នកដទៃ។ សូមព្រះជាម្ចាស់ប្រទានពរឲ្យបងប្អូន។

## ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនេះ យើងខ្ញុំជាគ្រីស្តបរិស័ទសូមអធិដ្ឋានអរព្រះគុណ និង ទូលអង្វរព្រះជាម្ចាស់សម្រាប់លោកអភិបាលទាំងបីភូមិភាគ



លោកអូលីវីយេ ផ្មឹតអីស្ស៊ែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ លោកអេរីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង លោកអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម។ សូមព្រះជាម្ចាស់ជាព្រះបិតា រួមជាមួយព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើងខ្ញុំដែលមានព្រះជន្មរស់ឡើងវិញ ប្រណីសន្តោស និងប្រទានសេចក្តីសុខសាន្ត សុភមង្គល កំលាំងពលំ និងបញ្ញាស្មារតីឈ្លៀសវៃ ដល់លោកអភិបាលទាំងបីក្នុងកិច្ចការប្រកាសដំណឹងល្អ និងក្នុងមុខងារជាគង្វាលនៃហ្វូងចៀមរបស់ព្រះជាម្ចាស់នៅលើទឹកដីកម្ពុជាដែលជាទីស្នេហារបស់លោក។

គោរពជូនពរពីការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក